ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIFRS 7

# ឧបករណ៍ហិរញ្ញវត្ថុ៖ ការលាតត្រដាងព័ត៌មាន

## Financial Instruments: Disclosures

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# អារម្ភកថា

ដោយសារនយោបាយ **"ឈ្នះ-ឈ្នះ"** របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្ដាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣"**, **"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨"**, **"យុទ្ធសាស្ត្រត្រីកោណ"**, **"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០"** និង **"យុទ្ធសាស្ត្រក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ២០១៤-២០១៨"** ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្ដីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្ដីពី **"ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា"** ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ” នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន “*ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង “*ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម*” ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ចី តាយី**

## គោលបំណង

១ គោលបំណងនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ គឺតម្រូវឱ្យបណ្តាអង្គភាពផ្តល់នូវការលាតត្រដាងនៅក្នុង របាយការណ៍ហិរញ្ញវត្ថុរបស់ពួកគេ ដែលអាចឱ្យអ្នកប្រើវាយតម្លៃ:

(ក) សារៈសំខាន់នៃឧបករណ៍ហិរញ្ញវត្ថុសម្រាប់ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុរបស់អង្គភាព

(ខ) ចរិតលក្ខណៈនិងវិសាលភាពនៃហានិភ័យដែលកើតចេញពីឧបករណ៍ហិរញ្ញវត្ថុដែលអង្គភាពចេញផ្សាយក្នុងអំឡុងការិយបរិច្ឆេទគណនេយ្យ និងនៅចុងការិយបរិច្ឆេទរាយការណ៍ និងរបៀប ដែលអង្គភាពគ្រប់គ្រងហានិភ័យទាំងនោះ។

២ គោលការណ៍នៅក្នុងស្តង់ដានេះបំពេញបន្ថែមគោលការណ៍ សម្រាប់ការទទួលស្គាល់ ការវាស់វែង និងការបង្ហាញទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុនៅក្នុងស្តង់ដាគណនេយ្យអន្តរជាតិ ៣២ *ឧបករណ៍ហិរញ្ញវត្ថុ: ការដាក់បង្ហាញ* និងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ *ឧបករណ៍ហិរញ្ញវត្ថុ*។

## គ្របខណ្ឌ

៣ ស្តង់ដានេះត្រូវអនុវត្តន៍ដោយគ្រប់អង្គភាពទាំងអស់ ចំពោះគ្រប់ប្រភេទឧបករណ៍ហិរញ្ញវត្ថុ, លើកលែងតែ:

(ក)ភាគកម្មនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ, ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុនដែលត្រូវបានកំណត់ដោយយោងតាមស្តង់ដាគណនេយ្យអន្តរជាតិ ២៧ *របាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក* ,ស្តង់ដាគណនេយ្យអន្តរជាតិ២៨*ការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ* ឬស្តង់ដាគណនេយ្យអន្តរជាតិ ៣១ *ការវិនិយោគនៅក្នុងក្រុមហ៊ុនរួមទុន*។ ទោះជាយ៉ាងណា នៅក្នុងករណីខ្លះ, ស្តង់ដាគណនេយ្យអន្តរជាតិ ២៧ ស្តង់ដាគណនេយ្យអន្តរជាតិ ២៨ ឬស្តង់ដាគណនេយ្យអន្តរជាតិ ៣១ អនុញ្ញាតិឲ្យ អង្គភាពរាប់បញ្ចូលភាគកម្ម នៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ, ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន ដោយប្រើស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តជាតិ ៩; នៅក្នុងករណីទាំងនោះ អង្គភាពទាំងអស់ត្រូវអនុវត្តន៍ការតម្រូវរបស់ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តជាតិ ៩ នេះ។ អង្គភាពទាំងអស់ក៏ត្រូវអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តជាតិ ៩ នេះចំពោះគ្រប់ដេរេវេទីវទាំអស់ ដែលពាក់ពន្ធ័នឹងភាគកម្ម នៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ, ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន ដរាបណា ដេរេវេទីវបំពេញបានតាមនិយមន័យនៃឧបករណ៍ ហិរញ្ញវត្ថុកម្មសិទ្ធិ នៅក្នុងស្តង់ដាគណនេយ្យអន្តរជាតិ៣២។

(ខ)សិទ្ធិនិងកាតព្វកិច្ចដែលកើតចេញពីផែនការអត្ថប្រយោជន៍និយោជិតនៃស្តង់ដាគណនេយ្យអន្តរជាតិ ១៩ *អត្ថប្រយោជន៍និយោជិត*

(គ) លុបចោល

(ឃ) កិច្ចសន្យាធានារ៉ាប់រងដូចបានកំណត់ នៅក្នុងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៤ *កិច្ចសន្យាធានារ៉ាប់រង*។ ទោះជាយ៉ាងណា ស្តង់ដានេះអនុវត្តន៍ចំពោះដេរេវេទីវដែលមានបង្កប់នៅក្នុងកិច្ចសន្យាធានារ៉ាប់រង

ប្រសិនបើស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ តម្រូវឲ្យអង្គភាពកំណត់ពួកវាដាច់ដោយឡែកពីគ្នា។ជាងនេះទៀត អ្នកបោះ ផ្សាយត្រូវអនុវត្តន៍ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះចំពោះ*កិច្ចសន្យាធានាហិរញ្ញវត្ថុ* ប្រសិនបើ អ្នកបោះផ្សាយអនុវត្តន៍ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ សម្រាប់ការទទួលស្គាល់និងវាស់វែងកិច្ចសន្យា, ប៉ុន្តែ ត្រូវអនុវត្តន៍ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៤ ប្រសិនបើអ្នកបោះផ្សាយជ្រើសរើស ដោយយោងតាមកថាខណ្ឌ ៤(ឃ) នៃស្តង់ដារបាយ-ការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៤ អនុវត្តស្តង់ដា របាយការណ៍ហិរញ្ញវត្ថុអន្តជាតិ ៤ សម្រាប់ការទទួលស្គាល់និងការវាស់វែងកិច្ចសន្យាធានារ៉ាប់រង។

(ង) ឧបករណ៍ហិរញ្ញវត្ថុ, កិច្ចសន្យានិងកាតព្វកិច្ច តាមប្រតិបត្តិការនៃការទូទាត់ ផ្អែកលើបណ្ណ័ភាគហ៊ុន ដែលស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ២ *ការទូទាត់ដោយផ្អែកលើបណ្ណ័ភាគហ៊ុន* អនុវត្តន៍,លើកលែងតែស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះអនុវត្តន៍ ចំពោះកិច្ចសន្យានានាដែលស្ថិតនៅក្នុងក្របខណ្ឌនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩។

(ច)ឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានតម្រូវឲ្យធ្វើចំណាត់ថ្នាក់ថាជាឧប-ករណ៍ ហិរញ្ញវត្ថុកម្មសិទ្ធិដោយអនុលោមតាម កថាខណ្ឌ ១៦ក និង ១៦ខ ឬកថាខណ្ឌ១៦គ និងកថាខណ្ឌ១៦ឃ នៃស្តង់ដាគណនេយ្យអន្តរជាតិ៣២។

៤ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះអនុវត្តន៍ សម្រាប់ការទទួលស្គាល់ និងការមិនទទួលស្គាល់ឧបករណ៍ហិរញ្ញវត្ថុ។ ឧបករណ៍ហិរញ្ញវត្ថុដែលទទួលស្គាល់រួមមានទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលស្ថិតនៅក្នុងក្របខណ្ឌ នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩។

ឧបករណ៍ហិរញ្ញវត្ថុ មិនទទួលស្គាល់រួមមានឧបករណ៍ហិរញ្ញវត្ថុមួយចំនួន បោះទោះបីជា ស្ថិតនៅក្រៅក្របខណ្ឌ នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ ដែលស្ថិតនៅក្នុងក្របខណ្ឌនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ (ដូចជា ការប្តេជ្ញាសងបំណុល)។

៥ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះអនុវត្តចំពោះកិច្ចសន្យាទិញ ឬលក់ផលិតផល មិនមែនហិរញ្ញវត្ថុដែលស្ថិត នៅក្នុងក្របខណ្ឌស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩។

## ប្រភេទថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុ និង កម្រិតនៃការលាតត្រដាងព័តមាន

៦ នៅពេលដែលស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ តម្រូវឱ្យមានការលាតត្រដាងតាមប្រភេទថ្នាក់ឧបករណ៍ហិរញ្ញវត្ថុ, អង្គភាព ត្រូវដាក់ជាក្រុមនូវឧបករណ៍ហិរញ្ញវត្ថុទាំងអស់ទៅតាមប្រភេទថ្នាក់ ដែលសមរម្យទៅតាមលក្ខណៈ នៃព័ត៌មានដែលបានលាតត្រដាងនិងដាក់បញ្ចូលផងដែរនូវចរិតលក្ខណៈរបស់ឧបករណ៍ហិរញ្ញវត្ថុទាំងនោះ។ អង្គភាព ត្រូវផ្តល់ឱ្យព័ត៌មានបានគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យមានការសម្របសម្រួល ចំពោះបណ្តាធាតុដែលបានបង្ហាញ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## សារៈសំខាន់នៃឧបករណ៍ហិរញ្ញវត្ថុសម្រាប់ស្ថានភាពហិរញ្ញវត្ថុនិងលទ្ធផលហិរញ្ញវត្ថុ

**៧ អង្គភាពត្រូវលាតត្រដាងព័ត៌មានដែលអាចឱ្យអ្នកប្រើរបាយការណ៍ហិរញ្ញវត្ថុវាយតម្លៃបានពីសារៈសំខាន់នៃឧបករណ៍ហិរញ្ញវត្ថុ សម្រាប់ស្ថានភាពហិរញ្ញវត្ថុនិងលទ្ធផលហិរញ្ញវត្ថុ។**

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

## ប្រភេទទ្រព្យសកម្មហិរញ្ញវត្ថុ និង បំណុលហិរញ្ញវត្ថុ

៨ តម្លៃលើបញ្ជីនៃប្រភេទនិមួយខាងក្រោម ដូចបានបញ្ជាក់នៅក្នុងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩, ត្រូវតែលាតត្រដាងនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឬនៅក្នុងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុ នូវៈ

(ក) ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែងតាមតម្លៃសមស្របនៅចុងការិយបរិច្ឆេទ ដោយបង្ហាញដាច់ដោយឡែកនូវ (១)ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកំណត់នៅការទទួលស្គាល់ដំបូង និង(២) ទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមច្បាប់កំណត់តាមតម្លៃសមស្របដោយយោងតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩។

(ខ)-(ឃ) លុបចោល

(ង) បំណុលហិរញ្ញវត្ថុ ដែលបានវាស់វែងតាមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទ ដោយបង្ហាញដាច់ដោយឡែកនូវ (១)ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកំណត់នៅការទទួលស្គាល់ដំបូង និង(២) ទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែង តាមច្បាប់កំណត់តាមតម្លៃសមស្រប ដោយយោងតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩។

(ច) ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃដករំលស់

(ឆ) បំណុលហិរញ្ញវត្ថុវាស់វែងតាមតម្លៃដករំលស់

(ជ) ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលវាស់វែង តាមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទនៅក្នុងចំណូលផ្សេងៗ

**ទ្រព្យសកម្មហិរញ្ញវត្ថុ ឬ បំណុលហិរញ្ញវត្ថុ វាស់វែងតាមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទ**

៩ ប្រសិនបើអង្គភាពត្រូវបានកំណត់ថាបានវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ (ឬ ក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុ) តាមតម្លៃសមស្រប បើមិនដូច្នោះទេ នឹងត្រូវវាស់វែងតាមតម្លៃដករំលស់, អង្គភាពត្រូវបង្ហាញៈ

(ក) កម្រិតប្រឈមអតិបរិមាទៅនឹងហានិភ័យឥណទាន (មើល កថាខណ្ឌ ៣៦(ក)) របស់ទ្រព្យសកម្មហិរញ្ញវត្ថុ (ឬ ក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុ) នៅចុងការិយបរិច្ឆេទរាយការណ៍។

(ខ) បរិមាណដែលនិសន្ទន្នឥណទានដែលពាក់ពន្ធ័ណាមួយ ឬឧបករណ៍ហិរញ្ញវត្ថុ ដែលស្រដៀងគ្នាសម្រាល នូវកម្រិតប្រឈមអតិបរមាទៅនឹងហានិភ័យឥណទាន។

(គ) បរិមាណនៃការប្រែប្រួល,នៅក្នុងអំឡុងពេលនិងគ្រាជាបន្តបន្ទាប់, នៅក្នុងតម្លៃសមស្របរបស់ទ្រព្យសកម្ម (ឬក្រុម នៃទ្រព្យសកម្មហិរញ្ញវត្ថុ) ដែលគួររាប់បញ្ចូលទៅនឹងការប្រែប្រួលនៅក្នុងហានិភ័យឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ

ដែលបានកំណត់ៈ

(១) ថាជាបរិមាណនៃបម្រែបម្រួលនៅក្នុងតម្លៃសមស្រប ដែលមិនអាចរាប់បញ្ចូលទៅនៅក្នុងបម្រែបម្រួល នៃលក្ខខណ្ឌទីផ្សារ ដែលនឹងធ្វើឲ្យកើនឡើងនូវហានិភ័យទីផ្សារ ឬ

(២) ប្រើវិធីសាស្ត្រផ្សេងមួយទៀតដែលអង្គភាពជឿថានឹងបង្ហាញ ដោយស្មោះត្រង់ជាង នូវបរិមាណនៃបម្រែបម្រួល នៅក្នុងតម្លៃ

សមស្រប ដែលអាចរាប់បញ្ចូលទៅនឹងបម្រែបម្រួល នៅក្នុងហានិភ័យឥណទានរបស់ទ្រព្យសកម្ម។

បម្រែបម្រួលលក្ខខណ្ឌទីផ្សារ ធ្វើឱ្យកើនហានិភ័យទីផ្សារ ដែលរួមមានបម្រែបម្រួលនៃអត្រាការប្រាក់បានអង្កេត(គម្រូ), ថ្លៃរបស់កុំម៉ូឌីធី, អត្រាប្តូរប្រាក់បរទេស ឬសន្ទស្សន៍ថ្លៃឬអត្រា។

(ឃ) បរិមាណបម្រែបម្រួលនៅក្នុងតម្លៃសមស្របនៃនិស្សន្ទឥណទានដែលពាក់ពន្ធ័ ឬឧបករណ៍ហិរញ្ញវត្ថុស្រដៀងដែល បានកើតឡើង នៅក្នុងអំឡុងពេល និងគ្រាជាបន្តបន្ទាប់ ចាប់តាំងពីទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកំណត់។

១០ ប្រសិនបើអង្គភាពបានកំណត់បំណុលហិរញ្ញវត្ថុតាមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទដោយយោងតាមកថាខណ្ឌ៤.២.២ នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ និងត្រូវបានតម្រូវឱ្យបង្ហាញផលប៉ះពាល់ នៃបម្រែបម្រួលនៅក្នុង ហានិភ័យរបស់បំណុលនោះ នៅក្នុងចំណូលបន្ទាប់បន្សំ (មើលកថាខណ្ឌ៥.៧.៧ នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩), អង្គភាពត្រូវដាក់បង្ហាញៈ

(ក) បរិមាណនៃបម្រែបម្រួល ដោយមានការបង្គរជាបន្តបន្ទាប់ នៃតម្លៃសមស្របរបស់បំណុលហិរញ្ញវត្ថុដែលអាចរាប់ បញ្ចូលទៅក្នុងបម្រែបម្រួលនៅក្នុងហានិភ័យឥណទានរបស់បំណុលនោះ(មើលកថាខណ្ឌ ខ៥.៧.១៣ ដល់កថាខណ្ឌ ខ៥.៧.២០ នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩ សម្រាប់ការណែនាំក្នុងការកំណត់ផលប៉ះពាល់ នៃបម្រែបម្រួលហានិភ័យឥណទានរបស់បំណុល)។

(ខ) ភាពខុសគ្នារវាងតម្លៃលើបញ្ជីរបស់បំណុលហិរញ្ញវត្ថុនិងបរិមាណ ដែលអង្គភាពត្រូវបានតម្រូវឱ្យបង់សង តាមកិច្ចសន្យានៅពេលដល់កំណត់សងទៅឱ្យអ្នកកាន់កាប់កាតព្វកិច្ច។

(គ) ការផ្ទេរណាមួយនៃចំណេញ ឬខាតបង្គរនៅក្នុងទ្រព្យម្ចាស់ក្នុងអំឡុងគ្រាដោយរួមបញ្ចូលនូវហេតុផលនៃការផ្ទេរ។

(ឃ) ប្រសិនបើបំណុលមិនត្រូវបានទទួលស្គាល់នៅក្នុងអំឡុងគ្រា បរិមាណ (ប្រសិនបើមាន) បានបង្ហាញនៅក្នុងចំណូលបន្ទាប់បន្សំ ដែលត្រូវបានទទួលស្គាល់នៅខណៈពេលនៃការមិនទទួលស្គាល់។

១០ក ប្រសិនបើ អង្គភាព កំណត់បំណុលហិរញ្ញវត្ថុតាមតម្លៃសមស្រប នាចុងការិយបរិច្ឆេទ ដោយយោងតាមកថាខណ្ឌ ៤.២.២ នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ និងត្រូវបានតម្រូវឱ្យបង្ហាញរាល់បម្រែបម្រួលក្នុងតម្លៃសមស្របរបស់បំណុលនោះ (ដោយទាំងផលប៉ះពាល់នៃ បម្រែបម្រួល នៅក្នុងហានិភ័យឥណទានរបស់បំណុលផងដែរ) នៅក្នុងរបាយការណ៍ចំណេញ ឬខាត (មើលកថាខណ្ឌ ៥.៧.៧ និង កថាខណ្ឌ ៥.៧.៨ នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩) អង្គភាពត្រូវបង្ហាញៈ

(ក) បរិមាណបម្រែបម្រួល, ក្នុងអំឡុងគ្រានិងគ្រាជាបន្តបន្ទាប់, នៅក្នុងតម្លៃសមស្របរបស់បំណុលហិរញ្ញវត្ថុ ដែលអាចរួមមានទាំងបម្រែបម្រួលនៅក្នុងហានិភ័យឥណទានរបស់បំណុល (មើលកថាខណ្ឌ ខ៥.៧.១៣ ដល់កថាខណ្ឌ ខ៥.៧.២០ នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ សម្រាប់ធ្វើជាសេចក្តីណែនាំក្នុងការកំណត់ផលប៉ះពាល់ នៃបម្រែបម្រួលនៅក្នុងហានិភ័យឥណទានរបស់បំណុល) និង

(ខ) ភាពខុសគ្នារវាងតម្លៃលើបញ្ជីរបស់បំណុលហិរញ្ញវត្ថុ និងបរិមាណដែលអង្គភាព នឹងត្រូវបានតម្រូវឱ្យសងតាមកិច្ចសន្យា នាកាលបរិច្ឆេទដល់កំណត់សងចំពោះម្ចាស់បំណុល (កាតព្វកិច្ច)។

១១ អង្គភាពត្រូវបង្ហាញផងដែរនូវៈ

(ក) ការបរិយាយលំអិតអំពីវិធីសាស្ត្រដែលប្រើ ដើម្បីអនុលោមតាមការតម្រូវនៅក្នុងកថាខណ្ឌ៩(គ), ១០(ក), និង ១០ក(ក) និងកថាខណ្ឌ ៥.៧.៧(ក) នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ ដោយរួមទាំងការពន្យល់ពីមូលហេតុ ដែលវិធិសាស្ត្រនោះមានភាពសមស្របផងដែរ។

(ខ)ប្រសិនបើ អង្គភាពជឿថា ការលាតត្រដាងដែលបានធ្វើ, ទាំងនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឬនៅក្នុងកំណត់សម្គាល់ របស់របាយ-ការណ៍ហិរញ្ញវត្ថុ, ដើម្បីអនុលោមតាមការតម្រូវនៅក្នុងកថាខណ្ឌ ៩(គ), ១០(ក) ឬ ១០ក(ក) ឬកថាខណ្ឌ៥.៧.៧នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ មិនបានបង្ហាញដ៏ត្រឹមត្រូវនូវបម្រែបម្រួល នៅក្នុងតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុឬបំណុលហិរញ្ញវត្ថុ ដែលអាចរួមមានទាំងបម្រែបម្រួលនៅក្នុងហានិភ័យឥណទានរបស់វា ហេតុផលដែលនាំដល់ការសន្និដ្ឋាននេះ និងកត្តាដែលអង្គភាពជឿជាក់ថាមានភាពពាក់ពន្ធ័។

(គ) ការបរិយាយលំអិតអំពីវិធីសាស្ត្រ ឬបណ្តាវិធីសាស្ត្រ ដែលបានប្រើដើម្បីកំណត់ថា ការបង្ហាញ អំពីផលប៉ះពាល់ នៃបម្រែបម្រួល នៅក្នុងហានិភ័យ ឥណទានរបស់បំណុលនៅក្នុងផ្នែកចំណូលបន្ទាប់បន្សំនឹងបង្កើតឬធ្វើឱ្យកាន់តែធំឡើងនូវភាពមិនស៊ីគ្នាផ្នែកគណនេយ្យនៅក្នុងរបាយការណ៍ចំណេញ ឬខាត(មើលកថាខណ្ឌ ៥.៧.៧ និង ៥.៧.៨ នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩)។ ប្រសិនបើអង្គភាពត្រូវបានតម្រូវឱ្យ

បង្ហាញនូវផលប៉ះពាល់ នៃបម្រែបម្រួល នៅក្នុងហានិភ័យឥណទានរបស់បំណុល នៅក្នុងរបាយការណ៍ចំណេញ ឬខាត (មើលកថាខណ្ឌ ៥.៧.៨ នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩), ការលាតត្រដាងត្រូវតែរាប់បញ្ចូលការបរិយាយលំអិតនៃទំនាក់ទំនងសេដ្ឋកិច្ចដែល បានបរិយាយនៅក្នុងកថាខណ្ឌ ខ៥.៧.៦ នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩។

(ឃ) ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែង តាមតម្លៃសមស្រប នៅក្នុងផ្នែកចំណូលបន្ទាប់បន្សំផ្សេងៗ។

## ទ្រព្យសកម្មហិរញ្ញវត្ថុបានវាស់វែងតាមតម្លៃសមស្របតាមរយៈផ្នែកចំណូលបន្ទាប់បន្សំផ្សេងៗ

១១ក ប្រសិនបើអង្គភាពបានកំណត់យកការវិនិយោគនៅក្នុងឧបករណ៍ហិរញ្ញវត្ថុនឹងត្រូវវាស់វែង តាមតម្លៃសមស្រប តាមរយៈផ្នែកចំណូលបន្ទាប់បន្សំផ្សេងៗដូចបានអនុញ្ញាតដោយកថាខណ្ឌ ៥.៧.៥ នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ អង្គភាពត្រូវបង្ហាញៈ

(ក) ការវិនិយោគ នៅក្នុងឧបករណ៍ហិរញ្ញវត្ថុណាមួយ ដែលត្រូវបានកំណត់យកសម្រាប់ការវាស់វែងតាមតម្លៃសមស្រប
តាមរយៈផ្នែកចំណូលបន្ទាប់ បន្សំផ្សេងៗ។

(ខ) ហេតុផលនៃការប្រើជម្រើសនៃការដាក់បង្ហាញផ្សេងនេះ

(គ) តម្លៃសមស្របរបស់ការវិនិយោគនិមួយៗ នៅចុងការិយបរិច្ឆេទរាយ-ការណ៍

(ឃ) ភាគលាភបានទទួលស្គាល់ នៅក្នុងអំឡុងការិយបរិច្ឆេទ ដោយត្រូវបង្ហាញដាច់ដោយឡែក ទៅតាមប្រភេទនៃការវិនិយោគ ដែលមិនទទួល

ស្គាល់ នៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ និងភាគលាភទាំងឡាយ ដែលពាក់ពន្ធ័នឹងការវិនិយោគ ដែលនៅសល់នាចុងការិយបរិច្ឆេទរាយ-ការណ៍។

(ង) ការផ្ទេរណាមួយនៃចំណេញ ឬខាត បានបង្គរដែលស្ថិតនៅក្នុងផ្នែកទ្រព្យម្ចាស់នៅក្នុងអំឡុងគ្រាដោយដាក់បញ្ចូល ហេតុផលនៃការផ្ទេរនោះផងដែរ។

១១ខ ប្រសិនបើ អង្គភាពមិនទទួលស្គាល់ការវិនិយោគនៅក្នុងឧបករណ៍ហិរញ្ញវត្ថុដែលបានវាស់វែងតាមតម្លៃសមស្រប តាមរយៈផ្នែកចំណូលបន្ទាប់បន្សំផ្សេងៗ នៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ អង្គភាពត្រូវបង្ហាញៈ

(ក) ហេតុផលនៃការលក់ចោលការវិនិយោគ

(ខ) តម្លៃសមស្របរបស់ការវិនិយោគ នៅចុងកាលបរិច្ឆេទ នៃការមិនទទួលស្គាល់

(គ) ចំណេញឬខាតបង្គរដោយការលក់ចោលការវិនិយោគ

## ការចាត់ថ្នាក់ឡើងវិញ

**១២--១២ក [លុបចោល]**

១២ខ អង្គភាពត្រូវបង្ហាញ ប្រសិនបើ នៅក្នុងការិយបរិច្ឆេទរាយការណ៍បច្ចុប្បន្ន ឬពីមុន អង្គភាពបានធ្វើការចាត់ថ្នាក់ឡើងវិញ នូវទ្រព្យសកម្មហិរញ្ញវត្ថុ ដោយយោងតាម កថាខណ្ឌ ៤.៤.១ នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩។ សម្រាប់ព្រឹត្តិការណ៍និមួយៗបែបនេះ អង្គភាពត្រូវបង្ហាញៈ

(ក) កាលបរិច្ឆេទនៃការធ្វើចំណាត់ថ្នាក់ឡើងវិញ។

(ខ) ការពន្យល់លំអិតនៃបម្រែបម្រួល នៅក្នុងម៉ូឌែលអាជីវកម្ម និងការបរិយាយ ជាលក្ខណៈគុណវុឌ្ឍនៃផលប៉ះពាល់ លើរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាព។

(គ) បរិមាណដែលបានបែងចែកចូលឬចេញពីប្រភេទនិមួយៗ។

១២គ សម្រាប់ការិយបរិច្ឆេទរាយការណ៍នីមួយៗ បន្ទាប់ពីការធ្វើចំណាត់ថ្នាក់ឡើងវិញរហូតដល់ការមិនទទួលស្គាល់ អង្គភាពត្រូវដាក់បង្ហាញនូវទ្រព្យសកម្មដែលបានចាត់ថ្នាក់ឡើងវិញ ដោយបែបនេះ ពួកវាត្រូវបានវាស់វែងតាមតម្លៃដករំលស់ ដោយយោងតាម កថាខណ្ឌ ៤.៤.១ នៃស្តង់ដាររបាយ-ការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩÷

(ក) អត្រាការប្រាក់ជាក់ស្តែងដែលបានកំណត់នាកាលបរិច្ឆេទ នៃការចាត់ថ្នាក់ឡើងវិញ និង

(ខ) ចំណូលការប្រាក់ ឬចំណាយការប្រាក់ដែលបានទទួលស្គាល់

១២ឃ ប្រសិនបើ អង្គភាពបានចាត់ថ្នាក់ឡើងវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុ ដោយបែបនេះពួកវាត្រូវបានវាស់វែងតាមតម្លៃដករំលស់ចាប់តាំងពីកាលបរិច្ឆេទរាយការណ៍ប្រចាំឆ្នាំចុងក្រោយរបស់អង្គភាព, អង្គភាពត្រូវដាក់បង្ហាញៈ

(ក) តម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅចុងការិយបរិច្ឆេទរាយ-ការណ៍ និង

(ខ) ចំណេញ ឬខាត ពីតម្លៃសមស្របដែលនឹងត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍ចំណេញ ឬខាត នៅក្នុងអំឡុងពេល នៃការិយបរិច្ឆេទរាយការណ៍ ប្រសិនបើ ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានគេធ្វើចំណាត់ថ្នាក់ឡើងវិញ។

១៣ [លុបចោល]

## ទ្រព្យដាក់បញ្ចាំ

១៤ អង្គភាពត្រូវដាក់បង្ហាញៈ

(ក) តម្លៃលើបញ្ជី នៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលខ្លួនបានដាក់បញ្ចាំធ្វើជាទ្រព្យដាក់បញ្ចាំ សម្រាប់បំណុល ឬបំណុលយថាហេតុ ដែលរួមមានទាំងបរិមាណ ដែលត្រូវបានធ្វើចំណាយថ្នាក់ឡើងវិញ ដោយយោងតាមកថាខណ្ឌ ៣.២.២៣(ក) នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ និង

(ខ) កិច្ចព្រមព្រៀងនិងលក្ខខណ្ឌពាក់ពន្ធ័នឹងការដាក់បញ្ចាំរបស់ខ្លួន។

១៥ នៅពេលអង្គភាពរក្សាទុកទ្រព្យដាក់បញ្ចាំ (របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ) ហើយត្រូវបានអនុញ្ញាតឲ្យលក់ ឬដាក់បញ្ចាំបន្តនូវទ្រព្យដាក់បញ្ចាំ នៅខណៈពេលដែលមិនមានការ មិនអាចសងបានរបស់ម្ចាស់នៃទ្រព្យដាក់បញ្ចាំ អង្គភាពត្រូវដាក់បង្ហាញៈ

(ក) តម្លៃសមស្របរបស់ទ្រព្យដាក់បញ្ចាំបានរក្សាទុក

(ខ) តម្លៃសមស្របនៃទ្រព្យដាក់បញ្ចាំដែលបានលក់ឬដាក់បញ្ចាំបន្ត និងកាតព្វកិច្ចដែលអង្គភាពត្រូវបង្វិលវិញនូវទ្រព្យដាក់បញ្ចាំ និង

(គ) កិច្ចព្រមព្រៀងនិងលក្ខខណ្ឌពាក់ពន្ធ័នឹងការប្រើប្រាស់ទ្រព្យដាក់បញ្ចាំ។

## គណនីសម្រាប់ការបន្ថែមទៅលើការខាតបង់ឥណទាន

១៦ នៅពេលទ្រព្យសកម្មហិរញ្ញវត្ថុបានថយចុះតម្លៃ ដោយសារតែការខាតបង់ឥណទាន ហើយអង្គភាពកត់ត្រានូវការថយចុះតម្លៃ នៅក្នុងគណនីដាច់

ដោយឡែកមួយ (ឧ.គណនីសម្រាប់ការបន្ថែមដែលបានប្រើ ដើម្បីកត់ត្រាការថយចុះតម្លៃនីមួយៗ ឬគណនីស្រដៀងគ្នាដែលបានប្រើ ដើម្បីកត់ត្រានូវការថយចុះតម្លៃសរុបរួមរបស់ទ្រព្យសកម្ម) ជាជាងបន្ថយដោយផ្ទាល់នូវតម្លៃរបស់ទ្រព្យសកម្ម, អង្គភាពត្រូវដាក់បង្ហាញនូវការសម្របសម្រួលនៃបម្រែបម្រួល នៅក្នុងគណនីនោះ នៅក្នុងអំឡុងពេល សម្រាប់ថ្នាក់នីមួយៗរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

### ឧបករណ៍ហិរញ្ញវត្ថុផ្សំដែលមាននិស្សន្ទបង្កប់ច្រើនប្រភេទ

១៧ ប្រសិនបើអង្គភាពបានចេញផ្សាយឧបករណ៍ហិរញ្ញវត្ថុមួយ ដែលរួមមានទាំងសមាសភាគជាបំណុលផងនិងទ្រព្យម្ចាស់ផង (មើលកថាខណ្ឌ ២៨ នៃស្តង់ដា គណនេយ្យអន្តរជាតិ ៣២) ហើយឧបករណ៍ហិរញ្ញវត្ថុមានសនិស្សន្ទបង្កប់ច្រើន ប្រភេទ ដែលមានតម្លៃអាស្រ័យលើគ្នាទៅវិញទៅមក (ដូចជា ឧបករណ៍ហិរញ្ញវត្ថុបំណុលអាចបម្លែងបានដែលអាចទិញមកវិញបាន), អង្គភាពត្រូវដាក់បង្ហាញនូវអត្ថិភាពនៃលក្ខណៈពិសេសទាំងនោះ។

## ការមិនសង និង ការរំលោភ

១៨ សម្រាប់បំណុលប្រាក់កម្ចីដែលបានទទួលស្គាល់នៅចុងការិយបរិច្ឆេទរាយការណ៍, អង្គភាពត្រូវដាក់បង្ហាញ:

(ក) សេចក្តីលំអិតស្តីពីការមិនសងណាមួយ នៅក្នុងអំឡុងការិយបរិច្ឆេទរបស់ប្រាក់ដើម ការប្រាក់ ទុនកប់ ឬលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនៃការសង វិញបំណុលប្រាក់កម្ចីទាំងនោះ

(ខ) តម្លៃលើបញ្ជីរបស់បំណុលប្រាក់កម្ចីដែលមិនសងនៅចុងការិយបរិច្ឆេទ និង

(គ) តើការមិនសងនោះនឹងត្រូវទទួលបានមកវិញឬទេ, ឬលក្ខខណ្ឌ នៃកិច្ចព្រមព្រៀងបំណុលប្រាក់កម្ចីត្រូវបានចចារឡើងវិញឬទេ មុនពេលដែល របាយលការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យចេញផ្សាយ។

១៩ ប្រសិនបើ, នៅក្នុងអំឡុងការិយបរិច្ឆេទ, មានវិវាទនៃកិច្ចព្រមព្រៀងប្រាក់កម្ចី ជាជាងអ្វីដែលបរិយាយនៅក្នុងកថាខណ្ឌ ១៨, អង្គភាពត្រូវដាក់បង្ហាញនូវព័ត៌មានដូចគ្នា ដូចដែលបានតម្រូវដោយកថាខណ្ឌ ១៨ ប្រសិនបើ វិវាទទាំងនោះអនុញ្ញាតឱ្យអ្នកឱ្យខ្ចីទាមទារនូវការទូទាត់សងបំណុលលឿនជាងមុន (ដរាបណា ការវិវាទត្រូវទទួលបានមកវិញនូវការ តបសង, ឬ លក្ខខណ្ឌនៃកិច្ចសន្យាត្រូវបានចរចារឡើងវិញ នៅចុងការិយបរិច្ឆេទរាយការណ៍ ឬនៅមុនចុងការិយបរិច្ឆេទរាយការណ៍)

## **របាយការណ៍ចំណូលសរុបរួម**

### **ធាតុនៃចំណូល, ចំណាយ, ចំណេញ ឬ ការខាត**

២០ អង្គភាពត្រូវដាក់បង្ហាញធាតុនៃចំណូល, ចំណាយ,ចំណេញ ឬ ការខាតបង់នៅក្នុងរបាយការណ៍ចំណូលសរុបរួម ឬនៅក្នុងកំណត់សំគាល់របស់របាយ-ការណ៍ហិរញ្ញវត្ថុ ដូចខាងក្រោម:

(ក) ចំណេញសុទ្ធ ឬ ការខាតសុទ្ធ ពី:

(១) ទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុវាស់វែងតាមតម្លៃសមស្របនៅក្នុងផ្នែករបាយការណ៍ចំណេញ ឬខាត ដោយបង្ហាញដាច់ដោយឡែកពីគ្នាតាមប្រភេទនៃទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុ

ដែលបានកំណត់ តាំងពីការទទួលស្គាល់ដំបូង, និងតាមប្រភេទ ចំណេញ ឬខាតលើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលត្រូវវាស់វែងតាមតម្លៃសមស្របតាមការកំណត់របស់ច្បាប់ ដោយយោងតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុ អន្តរជាតិ៩ (មានន័យថាបំណុលហិរញ្ញវត្ថុបំពេញបាននិយមន័យនៃការរក្សាទុកសម្រាប់ការជួញដូរនៅក្នុង ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩)។ ចំពោះបំណុលហិរញ្ញវត្ថុ ដែលបានកំណត់ តាមតម្លៃសមស្រប នៅក្នុងផ្នែករបាយការណ៍ចំណេញ ឬខាត, អង្គភាពត្រូវបង្ហាញដាច់ដោយឡែកពីគ្នានូវ បរិមាណនៃចំណេញ ឬខាត ដែលបានទទួលស្គាល់នៅក្នុងចំណូល បន្ទាប់បន្សំ និងបរិមាណដែលបានទទួលស្គាល់នៅក្នុងផ្នែករបាយ- ការណ៍ចំណេញឬខាត។

(២)--(៤) [លុបចោល]

(៥) បំណុលហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃដករំលស់

(៦) ទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃដករំលស់

(៧) ទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃសមស្រប នៅក្នុងផ្នែករបាយការណ៍ចំណូលបន្ទាប់បន្សំផ្សេងៗ

(ខ) ចំណូលការប្រាក់សរុបនិងចំណាយការប្រាក់សរុប (គណនាដោយការប្រើវិធីសាស្ត្រការប្រាក់ជាក់ស្តែង)ស ម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានវាស់វែងតាមតម្លៃរំលស់ ឬបំណុលហិរញ្ញវត្ថុដែលមិនត្រូវបានវាស់វែងតាមតម្លៃសមស្របនៅក្នុងផ្នែករបាយការណ៍ចំណេញ ឬខាត។

(គ) ចំណូល និងចំណាយជាប្រាក់កម្រៃ (ជាជាងបរិមាណ ដែលដាក់បញ្ចូល ក្នុងការគណនាអត្រាការប្រាក់ជាក់ស្តែង) ដែលបានមកពីៈ

(១) ទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃសមស្រប ឬបំណុលហិរញ្ញវត្ថុដែលមិនវាស់វែង តាមតម្លៃសមស្រប នៅក្នុងផ្នែករបាយការណ៍ ចំណេញឬខាត និង

(២) សកម្មភាពជាបរធនបាលកិច្ចនិងសកម្មភាពនៃកិច្ចសន្យាធានាផ្សេងៗ ដែលនាំឱ្យកើតមានការរក្សាទុក ឬការវិនិយោគទ្រព្យសកម្មក្នុងនាមរូបវន្តបុគ្គល, បរធនបាលកិច្ច, ផែនការផ្តល់កម្រៃសម្រាប់ការចូលនិវត្តន៍, និងស្ថានបណ្ណ៍ផ្សេងៗទៀត។

(ឃ) ចំណូលការប្រាក់លើទ្រព្យសកម្ម ដែលបានថយតម្លៃ ត្រូវបានបង្គរដោយយោងតាម កថាខណ្ឌ AG៣៩ នៃស្តង់ដាគណនេយ្យអន្តរជាតិ ៣៩ *ឧបករណ៍ហិរញ្ញវត្ថុៈការទទួលស្គាល់និងការវាស់វែង*។

(ង) បរិមាណនៃការខាតបង់ដោយការធ្លាក់ចុះតម្លៃសម្រាប់ថ្នាក់នីមួយៗនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

២០ក អង្គភាពត្រូវដាក់បង្ហាញនូវការវិភាគលើចំណេញ ឬខាត ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលសរុបរួម ដោយការមិនទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃដករំលស់ ដោយបង្ហាញដាច់ដោយឡែកពីគ្នា នូវចំណេញ ឬខាត ដែលកើតឡើងដោយការមិនទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទាំងនោះ។ការដាក់បង្ហាញនោះត្រូវដាក់បញ្ចូលផងដែរនូវហេតុផលនៃការមិនទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទាំងនោះ។

## ការដាក់បង្ហាញផ្សេងៗទៀត

## គោលនយោបាយគណនេយ្យ

២១ យោងតាម កថាខណ្ឌ ១១៧ នៃស្តង់ដាគណនេយ្យអន្តរជាតិ១ *ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ* (បានកែប្រែឡើង វិញនៅឆ្នាំ២០០៧), អង្គភាពលាតត្រដាង ដោយសេចក្តីសង្ខេប អំពីគោលនយោបាយគណនេយ្យ, មូលដ្ឋាននៃការវាស់វែង ដែលបានប្រើនៅក្នុងការរៀបចំ របាយការណ៍ហិរញ្ញវត្ថុ និងបណ្តាគោលនយោបាយគណនេយ្យផ្សេងៗ ដែលបានប្រើ ដែលជាប់ពាក់ពន្ធ័នឹងការយល់ដឹងអំពីរបាយការណ៍ហិរញ្ញវត្ថុ។

## គណនេយ្យទប់ស្កាត់ហានិភ័យ

២២ អង្គភាពត្រូវបង្ហាញធាតុខាងក្រោមដាច់ដោយឡែកពីគ្នា សម្រាប់ប្រភេទនីមួយៗ នៃការទប់ស្កាត់ហានិភ័យ ដែលបានបរិយាយនៅក្នុងស្តង់ដាគណនេយ្យអន្តរជាតិ ៣៩ (មានន័យថា ការទប់ស្កាត់ហានិភ័យតម្លៃសមស្រប, ការទប់ស្កាត់ហានិភ័យ, និងការទប់ស្កាត់ហានិភ័យវិនិយោគសុទ្ធនៅក្នុងប្រតិបត្តិការបរទេស)÷

(ក) ការបរិយាយប្រភេទនិមួយៗនៃការទប់ស្កាត់ហានិភ័យ

(ខ) ការបរិយាយនៃឧបករណ៍ហិរញ្ញវត្ថុដែលបានកំណត់ថាជា ឧបករណ៍សម្រាប់ទប់ស្កាត់ហានិភ័យ និងតម្លៃសមស្រប នៅចុងការិយបរិច្ឆេទរាយការណ៍ និង

(គ) ចរិតលក្ខណៈរបស់ហានិភ័យដែលត្រូវទប់ស្កាត់ហានិភ័យ

២៣ សម្រាប់ការទប់ស្កាត់ហានិភ័យលំហូរសាច់ប្រាក់, អង្គភាពត្រូវបង្ហាញៈ

(ក) បណ្តាការិយបរិច្ឆេទដែលលំហូរសាច់ប្រាក់រំពឹងថានឹងកើតឡើង និងពេលវេលាដែលពួកវានឹងមានផលប៉ះពាល់ដល់ចំណេញ ឬខាត

(ខ) ការបរិយាយនៃប្រតិបត្តិការដែលបានគ្រោងទុកសម្រាប់គណនេយ្យទប់ស្កាត់ហានិភ័យដែលបានប្រើពីមុន, ប៉ុន្តែ មិនរំពឹងថានឹងកើតឡើងវិញទៀត

(គ) បរិមាណទឹកប្រាក់ ដែលត្រូវទទួលស្គាល់ នៅក្នុងចំណូលបន្ទាប់បន្សំផ្សេងៗនៅក្នុងអំឡុងការិយបរិច្ឆេទ

(ឃ) បរិមាណទឹកប្រាក់ ដែលត្រូវបានចាត់ថ្នាក់ឡើងវិញ ពីទ្រព្យម្ចាស់ទៅរបាយការណ៍ចំណេញ ឬខាត សម្រាប់ការិយបរិច្ឆេទដោយបង្ហាញបរិមាណទឹកប្រាក់ ដែលបានដាក់បញ្ចូលនៅក្នុងធាតុនិមួយៗ នៅក្នុងរបាយការណ៍លទ្ធផលសរុបរួម និង

(ង) បរិមាណទឹកប្រាក់ដែលត្រូវដកចេញពីទ្រព្យម្ចាស់នៅក្នុងអំឡុងការិយបរិច្ឆេទ និងត្រូវដាក់បញ្ចូលទៅក្នុងថ្លៃដើមដំបូង ឬ បរិមាណលើបញ្ជីរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ឬបំណុលមិនមែនហិរញ្ញវត្ថុ ដែលការទិញ ឬការកើតឡើង គឺជាប្រតិបត្តិការដែលបានគ្រោងទុកប្រកបដោយលទ្ធភាពកើតឡើងខ្ពស់ដោយមានការទប់ស្កាត់ហានិភ័យ។

២៤ អង្គភាពត្រូវបង្ហាញដាច់ដោយឡែកពីគ្នានូវៈ

(ក) នៅក្នុងការទប់ស្កាត់ហានិភ័យតម្លៃសមស្រប, ចំណេញឬខាតលើៈ

(១) ឧបករណ៍ទប់ស្កាត់ហានិភ័យ និង

(២) ធាតុទប់ស្កាត់ហានិភ័យដែលអាចរួមមាននៅក្នុងហានិភ័យ ដែលបានទប់ស្កាត់។

(ខ) ភាពមិនមានប្រសិទ្ធិភាពដែលបានទទួលស្គាល់ នៅក្នុងរបាយការណ៍ចំណេញឬខាតដែលកើតឡើងពីការទប់ស្កាត់ ហានិភ័យលំហូរសាច់ប្រាក់។

(គ) ភាពមិនមានប្រសិទ្ធិភាពដែលបានទទួលស្គាល់ នៅក្នុងរបាយការណ៍ចំណេញ ឬខាត ដែលកើតឡើងពីការទប់ស្កាត់ហានិភ័យ នៃការវិនិយោគសុទ្ធនៅក្នុងប្រតិបត្តិការបរទេស។

## តម្លៃសមស្រប

២៥ លើកលែងនូវអ្វីដែលបានចែងនៅក្នុងកថាខណ្ឌ ២៩, ថ្នាក់និមួយៗ នៃទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុ (មើលកថាខណ្ឌ ៦), អង្គភាពត្រូវដាក់បង្ហាញតម្លៃសមស្របរបស់ថ្នាក់ នៃទ្រព្យសកម្មនិងបំណុលសកម្មតាមរបៀបមួយដែល អនុញ្ញាតវាត្រូវបានប្រៀបធៀបជាមួយនឹងតម្លៃលើបញ្ជីរបស់វា។

២៦ នៅក្នុងការដាក់បង្ហាញតម្លៃសមស្រប អង្គភាពត្រូវប្រមូលផ្តុំទ្រព្យសកម្មនិងបំណុលសកម្មទៅតាមថ្នាក់ៗ ប៉ុន្តែត្រូវកាត់ កងពួកវាតែទៅត្រឹមកម្រិតដែលតម្លៃសមស្រប ត្រូវបានកាត់កង នៅក្នុងរបាយការណ៍ ស្ថានភាពហិរញ្ញវត្ថុ។

២៧ អង្គភាពត្រូវដាក់បង្ហាញសម្រាប់ថ្នាក់និមួយៗរបស់ឧបករណ៍ហិរញ្ញវត្ថុ នូវវិធីសាស្រ្ត និងពេលវេលានៃការប្រើបច្ចេកទេសវាយតម្លៃ, សម្មតិកម្ម ដែលបានអនុវត្ត នៅក្នុងការកំណត់តម្លៃសមស្រប សម្រាប់ថ្នាក់នីមួយៗរបស់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ។ឧទាហរណ៍ ប្រសិនបើអនុវត្តបានអង្គភាពដាក់បង្ហាញព័ត៌មាន ស្តីអំពីសម្មតិកម្មទាក់ទងនឹងអត្រា នៃការបង់មុន, អត្រាប៉ាន់ស្មាននៃការខាតបង់ឥណទាន, និង អត្រាការប្រាក់ ឬអត្រាគុណតម្លៃបច្ចុប្បន្ន។ ប្រសិនបើ មានការផ្លាស់ប្តូរនូវបច្ចេកទេសវាយតម្លៃ អង្គភាពត្រូវដាក់បង្ហាញនូវការផ្លាស់ប្តូរនោះ និងហេតុផលនៃការផ្លាស់ប្តូរ។

២៧ក ដើម្បីដាក់បង្ហាញតាមការតម្រូវរបស់កថាខណ្ឌ ២៧ខ អង្គភាពត្រូវបែងចែកថ្នាក់នៃការវាស់វែងតម្លៃសមស្រប ដោយប្រើឋានុក្រមតម្លៃសមស្រប ដែលឆ្លុះបញ្ចាំងភាពជាដុំកំភួននៃធាតុចូល ដែលបានប្រើនៅក្នុងការវាស់វែង។ ឋានុក្រមនៃតម្លៃសមស្របត្រូវមានកម្រិតដូចខាងក្រោមៈ

(ក)ថ្លៃបានធ្វើសម្រង់ (មិនទាន់កែសម្រួល) នៅក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ឬបំណុលស្រដៀងគ្នា (កម្រិត១)

(ខ) ធាតុចូល ដែលមិនមែនជាថ្លៃបានធ្វើសម្រង់ដែលរួមមាន នៅក្នុងកម្រិត១ ដែលអាចអង្កេតបានសម្រាប់ទ្រព្យសកម្ម ឬបំណុល ដោយផ្ទាល់ (មានន័យថាជាថ្លៃ) ឬដោយប្រយោល (មានន័យថាបានមកពីថ្លៃ) (កម្រិត ២) និង

(គ) ធាតុចូលសម្រាប់ទ្រព្យសកម្ម ឬបំណុល ដែលមិនផ្អែកលើទិន្នន័យទីផ្សារ ដែលអាចអង្កេតបាន (ធាតុមិនអាចអង្កេតបាន) (កម្រិត៣)។

កម្រិតនៃឋានុក្រមតម្លៃសមស្របដែលការវាស់វែងតម្លៃសមស្របស្ថិតនៅត្រូវបានរៀបចំដាក់ជាប្រភេទនូវគ្រប់ទិដ្ឋភាព នឹងត្រូវបានកំណត់ ដោយផ្អែកលើមូលដ្ឋានកម្រិតទាបបំផុតដែលមានសារៈសំខាន់ ចំពោះការវាស់វែងតម្លៃសមស្រប គ្រប់ទិដ្ឋភាពទាំងអស់។ សម្រាប់គោលបំណងនេះ, សារៈសំខាន់នៃធាតុចូលមួយត្រូវបានគេប៉ាន់ស្មានធៀបនឹងការវាស់វែងតម្លៃសមស្របគ្រប់ទិដ្ឋភាពទាំងអស់។ ប្រសិនបើ ការវាស់វែងតម្លៃសមស្របមួយប្រើធាតុចូលដែលអាចអង្កេតបាន ដែលទាមទារនូវការកែសម្រួលជាដុំកំភួនដោយផ្អែកលើធាតុចូលដែលមិនអាចអង្កេតបាន, ការវាស់វែងនោះគឺជាការវាស់វែងកម្រិត៣។ ការវាយតម្លៃសារៈសំខាន់ នៃធាតុចូលជាក់លាក់ណាមួយសម្រាប់ការវាស់វែងតម្លៃសមស្របក្នុងគ្រប់ទិដ្ឋភាពទាំងអស់

ទាមទារនូវការវិនិច្ឆ័យ ដោយពិចារណានូវកត្តា ដែលមានភាពជាក់លាក់ចំពោះទ្រព្យសកម្មឬ បំណុលនោះ។

២៧ខ សម្រាប់ការវាស់វែងតម្លៃសមស្រប ដែលបានទទួលស្គាល់នៅក្នុងរបាយ-ការណ៍ស្ថានភាពហិរញ្ញវត្ថុ អង្គភាពត្រូវដាក់បង្ហាញសម្រាប់ថ្នាក់និមួយៗនៃឧបករណ៍ហិរញ្ញវត្ថុ:

(ក) កម្រិតនៅក្នុងឋានុក្រមតម្លៃសមស្របដែលការវាស់វែងតម្លៃសមស្របត្រូវបានដាក់តាមប្រភេទតាមគ្រប់ទិដ្ឋភាព ដោយញែកចេញនូវការវាស់វែងតម្លៃសមស្របដោយយោងតាមកម្រិតដែលបានកំណត់ នៅក្នុងកថាខណ្ឌ ២៧ក។

(ខ) ការផ្ទេរជាដុំកំភួនរវាងកម្រិត១និងកម្រិត២នៃឋានុក្រមតម្លៃសមស្រប និងហេតុផលនៃការផ្ទេរទាំងនោះ។ ការផ្ទេរទៅក្នុងកម្រិតនិមួយៗនឹងត្រូវបានដាក់បង្ហាញ និងពិភាក្សាដាច់ដោយឡែកពីការផ្ទេរចេញ នៃកម្រិតនិមួយៗ។ សម្រាប់គោលបំណងនេះសារៈសំខាន់ នឹងត្រូវបានគេវិនិច្ឆ័យដោយគោរពទៅតាមរបាយការណ៍ចំណេញ ឬខាត និងទ្រព្យសកម្ម សរុប និងបំណុលសរុប។

(គ) សម្រាប់ការវាស់វែងតម្លៃសមស្របនៅក្នុងកម្រិត ៣ នៃឋានុក្រមតម្លៃសមស្រប ការសម្របសម្រួលពីសមតុល្យ ដើមគ្រាទៅសមតុល្យចុងគ្រា ដោយដាក់បង្ហាញដាច់ដោយឡែក នូវការផ្លាស់ប្តូរ នៅក្នុងអំឡុងការិយបរិច្ឆេទ ដែលអាចរួមមានដូចខាងក្រោម:

(១) ចំណេញ ឬខាតសរុប សម្រាប់អំឡុងការិយបរិច្ឆេទ ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត និងបរិយាយទីតាំង

ដែលបានបង្ហាញ នៅក្នុងរបាយការណ៍លទ្ធផលសរុបរួម ឬនៅក្នុងរបាយការណ៍ចំណូលដាច់ដោយឡែក (ប្រសិនបើបានបង្ហាញ)

(២) ចំណេញ ឬខាតសរុប ដែលបានទទួលស្គាល់ នៅក្នុងចំណូលបន្ទាប់បន្សំផ្សេងៗ

(៣) ការទិញ ការលក់ ការបោះផ្សាយ និងការទូទាត់ (ប្រភេទនៃប្រតិបត្តិការនិមួយៗដាច់ដោយឡែកពីគ្នា) និង

(៤) ការផ្ទេរចូលឬការផ្ទេរចេញនៃកម្រិត ៣ (មានន័យថា ការផ្ទេរដែលអាចរួមបញ្ចូលនូវការផ្លាស់ប្តូរនៅក្នុងភាពអាចអង្កេតបាននៃទិន្នន័យទីផ្សារ) និងពិភាក្សាដាច់ដោយឡែកពីគ្នា ពីការផ្ទេរចេញនៃកម្រិត៣។

(ឃ) បរិមាណនៃចំណេញ ឬខាត សម្រាប់ការិយបរិច្ឆេទ នៅក្នុងចំណុច (គ)(១) ខាងលើរួមបញ្ចូលនូវក្នុងរបាយការណ៍ចំណេញ ឬខាត ដែលអាចរួមមានទាំងចំណេញ ឬខាត ទាក់ទងនឹងទ្រព្យសកម្ម និងបំណុលទាំងនោះដែលមាននៅចុង ការិយបរិច្ឆេទរាយការណ៍ និងការបរិយាយកន្លែង ដែលចំណេញ ឬខាត ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលសរុបរួម ឬនៅក្នុងរបាយការណ៍ចំណូលដាច់ដោយឡែក (ប្រសិនបើ មានបង្ហាញ)។

(ង) សម្រាប់ការវាស់វែងតម្លៃសមស្របនៅក្នុងកម្រិត ៣, ប្រសិនបើមានការផ្លាស់ប្តូរមួយ ឬច្រើននៃធាតុចូលចំពោះសម្មិតិកម្មផ្សេងទៀត ដែលមានភាពសមរម្យនឹងធ្វើឱ្យផ្លាស់ប្តូរតម្លៃសមស្របជាដុំកំភួន, អង្គភាព ត្រូវថែងពីព័ត៌មាន និង ដាក់បង្ហាញនូវផលប៉ះពាល់នៃការផ្លាស់ប្តូរទាំងនោះ។ អង្គភាពត្រូវបង្ហាញនូវផលប៉ះពាល់ នៃការផ្លាស់ប្តូរទៅនឹងសម្មិតិកម្មផ្សេងទៀតដែលសមរម្យដែលអាចកើតមាន ត្រូវបានគណនា។ សម្រាប់គោល

បំណងនេះ សារៈសំខាន់នឹង ត្រូវបានវិនិច្ឆ័យដោយយោងទៅតាមរបាយ-ការណ៍ចំណេញ ឬខាត, និងទ្រព្យសកម្មសរុបនិងបំណុលសរុប, ឬពេលដែលការផ្លាស់ប្តូរតម្លៃសមស្របត្រូវបានទទួលស្គាល់នៅក្នុងចំណូលបន្ទាប់បន្សំផ្សេងៗ, ទ្រព្យម្ចាស់សរុប។

អង្គភាពត្រូវបង្ហាញការលាតត្រដាងជាបរិមាណវិស័យដែលបានតម្រូវដោយកថាខណ្ឌនេះ នៅក្នុងទម្រង់ជាតារាង ដរាបណាមានទម្រង់ផ្សេងទៀត ដែលមានភាពសមរម្យជាង ។

២៨ ប្រសិនបើ ទីផ្សារសម្រាប់ឧបករណ៍ហិរញ្ញវត្ថុមិនសកម្ម, អង្គភាពបង្កើតតម្លៃសមស្របដោយខ្លួនឯង ដោយប្រើបច្ចេកទេស (មើលកថាខណ្ឌ ខ៥.៤.៦--កថាខណ្ឌខ៥.៤.១២ នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុ ៩)។ យ៉ាងណាក៏ដោយ ភស្តុតាងល្អបំផុតនៃតម្លៃសមស្រប នៅខណៈពេលនៃការទទួលស្គាល់លើកដំបូងគឺជាថ្លៃប្រតិបត្តិការ (មានន័យថា តម្លៃ សមស្របនៃការតបសងដែលបានផ្តល់ឲ្យឬបានទទួល), ដរាបណា លក្ខខណ្ឌដែលបានបរិយាយនៅក្នុងកថាខណ្ឌ ខ៥.៤.៨ នៃស្តង់ដា បាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ ត្រូវបានឆ្លើយតប។វាអាចមានភាពខុសគ្នារវាងតម្លៃសមស្របនៅខណៈពេលនៃការទទួលស្គាល់លើកដំបូងនិងបរិមាណ ដែលនឹងត្រូវបានកំណត់នៅកាលបរិច្ឆេទនោះ ដោយប្រើបច្ចេកទេស នៃការវាយតម្លៃ។ ប្រសិនបើភាពខុសគ្នានោះកើតឡើង អង្គភាពត្រូវដាក់បង្ហាញតាមថ្នាក់នៃឧបករណ៍ ហិរញ្ញវត្ថុៈ

(ក)គោលនយោបាយគណនេយ្យសម្រាប់ការទទួលស្គាល់នូវភាពខុសគ្នានៅក្នុងរបាយការណ៍ចំណេញ ឬខាត ដើម្បីឆ្លុះបញ្ចាំងការផ្លាស់ប្តូរនៃកត្តានានា (រួមទាំងពេលវេលាផង) ដែលអ្នកចូលរួម នៅក្នុងទីផ្សារនឹងត្រូវ

ពិចារណា ក្នុងការកំណត់ថ្លៃ (មើលកថាខណ្ឌ ខ៥.៤.៩ នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុ ៩) និង

(ខ)ភាពខុសគ្នាសរុបរួមដែលមិនទាន់បានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត នៅដើមការិយបរិច្ឆេទ និងចុងការិយបរិច្ឆេទ និងការសម្របសម្រួលនៃការផ្លាស់ប្តូរនៅក្នុង, សមតុល្យនៃភាពខុសគ្នានេះ។

២៩ ការលាតត្រដាងព័ត៌មានមិនតម្រូវឡើយៈ

(ក)នៅពេលដែលតម្លៃលើបញ្ជីមានបរិមាណប្រហាក់ប្រហែលនឹងតម្លៃសមស្រប, ឧទាហរណ៍ ឧបករណ៍ហិរញ្ញវត្ថុ ដូចជា គណនីត្រូវទាររយៈពេលខ្លី និងគណនីត្រូវសងរយៈពេលខ្លី

(ខ) [លុបចោល]

(គ) សម្រាប់កិច្ចសន្យា ដែលរួមមានលក្ខណៈ នៃការចូលរួមពាក់ពន្ធ័នឹងការសម្រេចចិត្ត (ដូចបរិយាយនៅក្នុងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុ ៤) ប្រសិនបើ តម្លៃសមស្របនៃលក្ខណៈនោះមិនអាចវាស់វែងដ៏គួរឲ្យទុកចិត្តបាន។

៣០ នៅក្នុងបណ្តាករណីដូចបានបរិយាយនៅក្នុងកថាខណ្ឌ ២៩(គ), អង្គភាពត្រូវបង្ហាញព័ត៌មានដែលជួយអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ធ្វើការវិនិច្ឆ័យផ្ទាល់ខ្លួនរបស់គេអំពីកម្រិតនៃភាពខុសគ្នាដែលអាចមានរវាងតម្លៃលើបញ្ជីនៃកិច្ច សន្យាទាំងនោះជាមួយនឹងតម្លៃសមស្រប ដោយរួមមានទាំងៈ

(ក)ហេតុការណ៍ដែលព័ត៌មានអំពីតម្លៃសមស្របមិនត្រូវបានលាតត្រដាងសម្រាប់ឧបករណ៍ហិរញ្ញវត្ថុទាំងនេះ ពីព្រោះតម្លៃសមស្រប មិនអាចត្រូវបានវាស់វែងដោយជឿជាក់,

(ខ) ការបរិយាយអំពីឧបករណ៍ហិរញ្ញវត្ថុ, តម្លៃលើបញ្ជីរបស់ពួកវា, និង ការពន្យល់អំពីមូលហេតុ ដែលតម្លៃសមស្រប មិនអាចត្រូវបានវាស់វែង ដោយជឿជាក់,

(គ) ព័ត៌មានអំពីទីផ្សារសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ

(ឃ) ព័ត៌មានអំពីបំណងនិងរបៀប ដែលអង្គភាព លក់ចោលឧបករណ៍ ហិរញ្ញវត្ថុ និង

(ង)ប្រសិនបើ ឧបករណ៍ហិរញ្ញវត្ថុ ដែលតម្លៃសមស្របរបស់វាពីមុន មិន អាចត្រូវបានវាស់វែងដោយជឿជាក់បាន មិនត្រូវបានគេទទួលស្គាល់ ដែល ហេតុការណ៍នោះ តម្លៃសមស្របនៅពេលនៃការមិនទទួលស្គាល់ និង បរិមាណនៃចំណេញ ឬខាត ដែលបានទទួលស្គាល់។

## ចរិតលក្ខណៈនិងទំហំនៃហានិភ័យដែលកើតឡើងពីឧបករណ៍ហិរញ្ញវត្ថុ

៣១ **អង្គភាពត្រូវដាក់បង្ហាញព័ត៌មានដែលអាចឱ្យអ្នកប្រើរបាយការណ៍ ហិរញ្ញវត្ថុ វាយតម្លៃបានពីចរិតលក្ខណៈ និងទំហំនៃហានិភ័យដែលកើតចេញពី ឧបករណ៍ហិរញ្ញវត្ថុ ដែលអង្គភាព ត្រូវប្រឈមនៅចុងការិយបរិច្ឆេទ របាយការណ៍។**

៣២ ការលាតត្រដាងព័ត៌មានដែលបានតម្រូវដោយកថាខណ្ឌ៣៣-កថាខណ្ឌ៤២ ផ្តោតលើហានិភ័យដែលកើតចេញពីឧបករណ៍ហិរញ្ញវត្ថុ និងវិធីនៃការគ្រប់ គ្រងហានិភ័យ។ ហានិភ័យទាំងនេះរួមមាន ប៉ុន្តែមិនអស់ត្រឹមនេះឡើយ ហានិភ័យឥណទាន, ហានិភ័យសន្ទនីយភាព និងហានិភ័យទីផ្សារ។

៣១ក ដោយផ្តល់នូវការលាតត្រដាងមានលក្ខណៈគុណវិស័យនៅក្នុងបរិបទ នៃ ការលាតត្រដាងមានលក្ខណៈបរិមាណវិស័យ អាចឱ្យអ្នកប្រើប្រាស់ផ្សារ

ភ្ជាប់ការលាតត្រដាងដែលពាក់ព័ន្ធ និងបង្កើតទម្រង់ពេញលេញមួយអំពីចរិតលក្ខណៈនិងទំហំនៃហានិភ័យដែលកើតចេញពីឧបករណ៍ហិរញ្ញវត្ថុ។ អន្តរសកម្មរវាងការលាតត្រដាងមានលក្ខណៈគុណវិស័យនិងការលាតត្រដាងមានលក្ខណៈបរិមាណវិស័យរួមចំណែកលាតត្រដាងព័ត៌មានកាន់តែប្រសើរឡើងដែលអាចឲ្យអ្នកប្រើ វាយតម្លៃការប្រឈមរបស់អង្គភាពទៅនឹងហានិភ័យ។

## ការលាតត្រដាងមានលក្ខណៈគុណវិស័យ

៣៣ សម្រាប់ប្រភេទនិមួយៗនៃហានិភ័យដែលកើតចេញពីឧបករណ៍ហិរញ្ញវត្ថុ អង្គភាពត្រូវលាតត្រដាងនូវៈ

(ក) ការប្រឈមទៅនឹងហានិភ័យ និងរបៀបដែលហានិភ័យកើតឡើង

(ខ) កម្មវត្ថុ, គោលនយោបាយ និងដំណើរការ សម្រាប់ការគ្រប់គ្រងហានិភ័យ និងវិធីសាស្ត្រដែលប្រើដើម្បីវាស់វែង ហានិភ័យ និង

(គ) ការផ្លាស់ប្តូរណាមួយនៅក្នុង (ក) ឬ (ខ) កើតឡើងពីគ្រាមុន។

## ការលាតត្រដាងមានលក្ខណៈបរិមាណវិស័យ

៣៤ សម្រាប់ប្រភេទនិមួយៗនៃហានិភ័យដែលកើតចេញពីឧបករណ៍ហិរញ្ញវត្ថុ អង្គភាពត្រូវលាតត្រដាងនូវៈ

(ក) សេចក្តីសង្ខេប, ទិន្នន័យជាបរិមាណវិស័យ ស្តីអំពីការប្រឈមរបស់អង្គភាព ចំពោះហានិភ័យ នៅចុងការិយបរិច្ឆេទរាយការណ៍។ការលាតត្រដាងនេះត្រូវផ្អែកលើព័ត៌មាន ដែលបានផ្តល់ឲ្យ ដោយផ្ទៃក្នុងចំពោះបុគ្គលគ្រប់គ្រងសំខាន់របស់អង្គភាព (ដូចបានកំណត់ នៅក្នុងស្តង់ដា

គណនេយ្យអន្តរជាតិ ២៤ *ការលាតត្រដាងព័ត៌មានរបស់ភាគីពាក់ព័ន្ធ*), ឧទាហរណ៍ ក្រុមប្រឹក្សាភិបាលរបស់អង្គភាព ឬ នាយកប្រតិបត្តិ។

(ខ) ការលាតត្រដាងដែលតម្រូវដោយ កថាខណ្ឌ៣៦ -៤២, ចំពោះទំហំដែលមិនបានផ្តល់ឲ្យ យោងតាមចំណុច(ក)

(គ) ការប្រមូលផ្តុំហានិភ័យ ប្រសិនបើមិនឃើញមាន នៅក្នុងការលាតត្រដាងដែលបានធ្វើ ដោយយោងតាមចំណុច

(ក)និង ចំណុច(ខ)

៣៥ ប្រសិនបើទិន្នន័យជាបរិមាណវិស័យដែលបានបង្ហាញនៅចុងការិយបរិច្ឆេទរាយការណ៍មិនតំណាងឲ្យការប្រឈមទៅ នឹងហានិភ័យរបស់អង្គភាព នៅក្នុងអំឡុងការិយបរិច្ឆេទ អង្គភាពត្រូវផ្តល់ឲ្យនូវព័ត៌មានបន្ថែមដែលតំណាងឲ្យការប្រឈមនឹងហានិភ័យ។

## ហានិភ័យឥណទាន

៣៦ អង្គភាពត្រូវលាតត្រដាងតាមថ្នាក់របស់ឧបករណ៍ហិរញ្ញវត្ថុៈ

(ក) បរិមាណដែលតំណាងដ៏ល្អ នៃការប្រឈមចំពោះហានិភ័យឥណទាននៅចុងការិយបរិច្ឆេទរាយកាណ៍ដោយមិនរាប់ បញ្ចូលទ្រព្យដាក់បញ្ចាំនានាដែលបានរក្សាទុក ឬការធ្វើឲ្យប្រសើរឡើងនៃឥណទានផ្សេងៗទៀត (មានន័យថាការធ្វើកិច្ចព្រមព្រៀងដែលមិនមានលក្ខណៈសម្បត្តិសម្រាប់កាត់កងដោយយោងតាមស្តង់ដាគណនេយ្យអន្តរជាតិ៣២), ការលាតត្រដាងនេះមិនបានតម្រូវសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ដែលមានតម្លៃលើបញ្ជីដែលជាតំណាងដ៏ល្អនូវការប្រឈមទៅនឹងហានិភ័យឥណទាន។

(ខ) ការបរិយាយអំពី ទ្រព្យដាក់បញ្ចាំបានរក្សាទុក និងការធ្វើឲ្យប្រសើរឡើងនៃឥណទានផ្សេងៗទៀត, និងផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ (មានន័យថា ការកំណត់បរិមាណនៃទំហំដែលទ្រព្យដាក់បញ្ចាំ និងការធ្វើឲ្យប្រសើរឡើង នៃឥណទានផ្សេងៗទៀត ធ្វើឲ្យសម្រាលដល់ហានិភ័យឥណទាន) ដោយយោងតាមបរិមាណ ដែលតំណាងដ៏ល្អនូវការប្រឈមជាអតិបរមាទៅនឹងហានិភ័យឥណទាន (ទោះជាបានបង្ហាញនៅក្នុង(ក) ឬបានតំណាងដោយតម្លៃលើបញ្ជីនៃឧបករណ៍ហិរញ្ញវត្ថុ)។

(គ) ព័ត៌មានអំពីគុណភាពឥណទានរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនទាន់ហួសកណត់សង ឬមិនទាន់ធ្លាក់ចុះតម្លៃ។

(ឃ)[ លុបចោល ]

*ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនទាន់ហួសកំណត់សង ឬមិនទាន់ធ្លាក់ចុះតម្លៃ*

៣៧ អង្គភាពត្រូវលាតត្រដាងតាមថ្នាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុៈ

(ក)ការវិភាគអាយុកាលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលហួសកំណត់សងនៅចុងការិយបរិច្ឆេទរាយការណ៍ប៉ុន្តែមិនទាន់ធ្លាក់ចុះតម្លៃ និង

(ខ)ការវិភាគទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកំណត់ដាច់ដោយឡែកៗពីគ្នា ដែលនឹងត្រូវធ្លាក់ចុះតម្លៃនាចុងការិយបរិច្ឆេទរាយការណ៍ ដោយរួមមានទាំងកត្តាដែលអង្គភាពពិចារណានៅក្នុងការកំណត់ថា ទ្រព្យសកម្មហិរញ្ញវត្ថុនោះនឹងធ្លាក់ចុះ តម្លៃ។

(គ) [លុបចោល ]

ទ្រព្យដាក់បញ្ចាំនិងការធ្វើឲ្យប្រសើរឡើងនៃឥណទានផ្សេងៗទៀត ដែលបានទទួល

៣៨ នៅពេលអង្គភាពទទួលបានទ្រព្យសកម្មហិរញ្ញវត្ថុនិងទ្រព្យសកម្ម មិនមែនហិរញ្ញវត្ថុ នៅក្នុងអំឡុងការិយបរិច្ឆេទដោយទទួលយកទ្រព្យដាក់បញ្ចាំ ឬក៏ស្នើសុំការធ្វើឱ្យប្រសើរឡើង នៃឥណទានផ្សេងៗទៀត (ឧទាហរណ៍ការធានា),ហើយទ្រព្យសកម្មទាំងនោះឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ នៅក្នុងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិផ្សេងទៀត, អង្គភាពត្រូវលាតត្រដាងនូវទ្រព្យសកម្ម ដែលបានរក្សាទុកទាំងនោះនៅកាលបរិច្ឆេទរយការណ៍ៈ

(ក) ចរិតលក្ខណៈនិងតម្លៃលើបញ្ជីរបស់ទ្រព្យសកម្ម និង

(ខ) នៅពេលទ្រព្យសកម្មមិនមានងាយបម្លែងទៅជាសាច់ប្រាក់, គោលនយោបាយរបស់ក្រុមហ៊ុននៅក្នុងការបោះបង់ចោលទ្រព្យសកម្មបែបនោះ ឬគោលនយោបាយប្រើប្រាស់ទ្រព្យសកម្មទាំងនោះនៅក្នុងប្រតិបត្តិការ។

**ហានិភ័យសន្ទនីយភាព**

៣៩ អង្គភាពត្រូវលាតត្រដាងៈ

(ក) ការវិភាគលើភាពដល់កំណត់សងរបស់បំណុលហិរញ្ញវត្ថុ ដែលមិនមាននិស្សន្ទ (រួមមានការធានានិងកិច្ចសន្យាដែលបានចេញផ្សាយ) ដែលបង្ហាញនូវកាលវេលាដល់កំណត់សងតាមកិច្ចសន្យាដែលនៅសេសសល់)។

(ខ) ការវិភាគលើភាពដល់កំណត់សងរបស់បំណុលហិរញ្ញវត្ថុ ដែលមាននិស្សន្ទ។ ការវិភាគលើភាពដល់កំណត់សងត្រូវ រួមមាននូវកាលវេលាដល់កំណត់សង តាមកិច្ចសន្យាដែលនៅសល់ ដែលកាលវេលាដល់កំណត់សងតាមកិច្ចសន្យាគឺជាផ្នែកដ៏សំខាន់សម្រាប់ការយល់ដឹង អំពីពេលវេលា នៃលំហូរសាច់ប្រាក់(មើល កថាខណ្ឌ ខ១១ខ)។

(គ) ការបរិយាយរបៀបនៃការគ្រប់គ្រងហានិភ័យសន្ទនីយភាព ដែលមាននៅក្នុង(ក) និង(ខ)។

**ហានិភ័យទីផ្សារ**

*ការវិភាគវេទយិតភាព*

៤០ ដរាបណា អង្គភាពអនុលោមតាមកថាខណ្ឌ៤១, អង្គភាពត្រូវលាតត្រដាងៈ

(ក) ការវិភាគភាពងាយប្រែប្រួល សម្រាប់ប្រភេទនិមួយៗ នៃហានិភ័យទីផ្សារ ដែលអង្គភាពត្រូវប្រឈមនៅចុងការិយបរិច្ឆេទរាយការណ៍, បង្ហាញផលប៉ះពាល់លើចំណេញ ឬខាត និងទ្រព្យម្ចាស់ ដែលបណ្តាលមកពីការផ្លាស់ប្តូរ នៅក្នុងអថេរហានិភ័យដែលពាក់ព័ន្ធ ដែលអាចកើតមានឡើងនាកាលបរិច្ឆេទនោះ,

(ខ) វិធីសាស្ត្រ និងសម្មតិកម្មនានា ដែលបានប្រើនៅក្នុងការរៀបចំការវិភាគវេទយិតភាព និង

(គ) ការផ្លាស់ប្តូពីការិយបរិច្ឆេទមុននូវវិធីសាស្ត្រនិងសម្មតិកម្ម ដែលបានប្រើ និងហេតុផលនៃការផ្លាស់ប្តូរនោះ។

៤១ ប្រសិនបើ អង្គភាពរៀបចំការវិភាគវេទយិតភាព, ដូចជា វីធីសាស្ត្រកំណត់តម្លៃតាមហានិភ័យ,ដែលឆ្លុះបញ្ចាំងអំពីអន្តរានិស្សរភាពរវាងអថេរហានិភ័យ (ឧទាហរណ៍ អត្រាការប្រាក់និងអត្រាប្តូរប្រាក់) និងការប្រើប្រាស់វា ដើម្បីគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ, អង្គភាពអាចប្រើការវិភាគវេទយិតភាពជំនួសការវិភាគ ដែលបានបញ្ជាក់នៅក្នុង កថាខណ្ឌ ៤០។ អង្គភាពត្រូវដាក់បង្ហាញៈ

(ក) ការពន្យល់ដែលបានប្រើនៅក្នុងការរៀបចំការវិភាគវេទយិតភាព, និងប៉ារ៉ាម៉ែត្រសំខាន់ៗ និងសម្មតិកម្មដែលប្រើសម្រាប់វិភាគទិន្នន័យ ដែលបានផ្តល់ឲ្យ, និង

(ខ) ការពន្យល់ពីគោលបំណង នៃវិធីសាស្ត្រដែលបានប្រើ និងព្រំដែនកំណត់ដែលអាចធ្វើឲ្យព័ត៌មានមិនឆ្លុះបញ្ចាំងពេញលេញនូវតម្លៃសមស្របរបស់ទ្រព្យសកម្មនិងបំណុលដែលពាក់ពន្ធ័។

*ការលាតត្រដាងព័ត៌មានអំពីហានិភ័យទីផ្សារសផ្សេងៗទៀត*

៤២ នៅពេលការវិភាគវេទយិតភាពត្រូវបានបង្ហាញដោយយោងតាម កថាខណ្ឌ ៤០ ឬកថាខណ្ឌ ៤១ មិនតំណាងឲ្យហានិភ័យដែលមាននៅក្នុងឧបករណ៍ហិរញ្ញវត្ថុ (ឧទាហរណ៍ ដោយការការប្រឈមហានិភ័យ នៅចុងឆ្នាំមិនឆ្លុះបញ្ចាំងការប្រឈម ហានិភ័យនៅក្នុនុងអំឡុងឆ្នាំ), អង្គភាពត្រូវលាតត្រដាង

នូវហេតុការណ៍និងហេតុផល ដែលខ្លួនជឿថាការវិភាគវេទយិតភាព មិនតំណាងឲ្យការប្រឈមហានិភ័យ។

## ការផ្ទេរហានិភ័យរបស់ទ្រព្យសកម្ម

៤២ក ការតម្រូវសម្រាប់ការលាតត្រដាងនៅក្នុងកថាខណ្ឌ ៤2ខ-៤២ច ទាក់ទងនឹងការផ្ទេរទ្រព្យសកម្មហិរញ្ញវត្ថុបំពេញបន្ថែម ការតម្រូវ សម្រាប់ការលាតត្រដាងផ្សេងៗទៀតនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុនេះ។ អង្គភាព ត្រូវបង្ហាញការលាតត្រដាងដែលបានតម្រូវដោយកថាខណ្ឌ ៤2ខ-៤២ច នៅក្នុងសេចក្តីសំគាល់តែមួយ ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។ អង្គភាព ត្រូវផ្តល់នូវការលាតត្រដាងដែលបានតម្រូវសម្រាប់គ្រប់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានផ្ទេរ ដែលមិនត្រូវបានទទួលស្គាល់ និងសម្រាប់ការពាក់ព័ន្ធបន្តនៅក្នុងទ្រព្យសកម្មដែលបានផ្ទេរ,ដែលអត្ថិភាពនៅកាលបរិច្ឆេទរាយការណ៍, ដោយមិនគិតដល់ពេលវេលានៃប្រតិបត្តិការផ្ទេរបានកើតឡើងឡើយ។ សម្រាប់គោលបំណងនៃការអនុវត្តការតម្រូវសម្រាប់ការលាតត្រដាងនៅក្នុងកថាខណ្ឌទាំងនោះ, អង្គភាពផ្ទេរទាំងអស់ ឬមួយផ្នែកនៃទ្រព្យសកម្មហិរញ្ញវត្ថុ (ទ្រព្យសកម្មហិរញ្ញវត្ថុបានផ្ទេរ) ក្នុងករណីនិងតែក្នុងករណីដែលអង្គភាពៈ

(ក) ផ្ទេរសិទ្ធិ តាមកិច្ចសន្យា ដើម្បីទទួលបានលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មហិរញ្ញវត្ថុនោះ ឬ

(ខ) រក្សាទុកសិទ្ធិតាមកិច្ចសន្យា ដើម្បីទទួលបានលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មហិរញ្ញវត្ថុនោះ, ប៉ុន្តែបន្តកាតព្វកិច្ច តាមកិច្ចសន្យា ដើម្បីបង់សាច់ប្រាក់ទៅឲ្យអ្នកទទួលមួយឬច្រើននាក់នៅក្នុងការរៀបចំមួយ។

៤២ខ អង្គភាព ត្រូវលាតត្រដាងព័ត៌មាន ដែលអាចឲ្យអ្នកប្រើរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន៖

(ក) យល់ពីទំនាក់ទំនងរវាងទ្រព្យសកម្មហិរញ្ញវត្ថុបានផ្ទេរ ដែលមិនត្រូវបានទទួលស្គាល់ទាំងស្រុង និងបំណុលពាក់ព័ន្ធ និង

(ខ) វាយតម្លៃចរិតលក្ខណៈនៃភាពពាក់ព័ន្ធជាបន្ត,ហានិភ័យពាក់ព័ន្ធ នៃភាពពាក់ព័ន្ធជាបន្តរបស់អង្គភាពជាមួយនឹងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនទទួលស្គាល់។

៤២គ សម្រាប់គោលបំណងនៃការអនុវត្តការតម្រូវសម្រាប់ការលាតត្រដាង នៅក្នុងកថាខណ្ឌ ៤២ង-៤២ច, អង្គភាព មានការពាក់ព័ន្ធជាបន្តនៅក្នុងទ្រព្យសកម្មហិរញ្ញវត្ថុបានផ្ទេរ ប្រសិនបើមាន,ដែលជាផ្នែកមួយនៃការផ្ទេរ, អង្គភាពរក្សាទុកសិទ្ធិតាមកិច្ចសន្យា ឬកាតព្វកិច្ចណាមួយ ដែលមាននៅក្នុងទ្រព្យសកម្មបានផ្ទេរ ឬទទួលសិទ្ធិតាមកិច្ចសន្យាឬកាតព្វកិច្ចថ្មីទាក់ទងនឹងទ្រព្យសកម្មហិរញ្ញវត្ថុបានផ្ទេរ។សម្រាប់គោលបំណងនៃការអនុវត្តការតម្រូវសម្រាប់ការលាតត្រដាងនៅក្នុងកថាខណ្ឌ៤២ង-៤២ច, ចំណុចខាងក្រោមមិនធ្វើបតិដ្ឋាការជាប់ទាក់ទងបន្តឡើយ៖

(ក) ការបង្ហាញ និងការធានាធម្មតាទាក់ទងនឹងការផ្ទេរមិនសុចរិត និងគោលការណ៍នៃភាពសមហេតុផល, សុចរិតនិងដំណោះស្រាយសមរម្យ ដែលអាចមិនមានសុពលភាព ចំពោះការផ្ទេរមួយ ដែលកើតចេញពីសកម្មភាពផ្លូវច្បាប់

(ខ) កិច្ចសន្យាអនាគត,កិច្ចសន្យាជម្រើសពិសេសនិងកិច្ចសន្យាផ្សេងទៀតដើម្បីទិញមកវិញនូវទ្រព្យសកម្មបានផ្ទេរ ដែលថ្លៃកិច្ចសន្យា (ថ្លៃសម្រាប់អនុវត្ត) គឺជាតម្លៃសមស្របរបស់ទ្រព្យសកម្មបានផ្ទេរ ឬ

(គ)កិច្ចព្រមព្រៀងដែលអង្គភាពរក្សាទុកសិទ្ធិតាមកិច្ចសន្យា ដើម្បីទទួលបានលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មហិរញ្ញវត្ថុមួយ ប៉ុន្តែបន្តទទួលយកកាតព្វកិច្ចតាមកិច្ចសន្យាដើម្បីបង់សងសាច់ប្រាក់ទៅអង្គភាពមួយឬអង្គភាពច្រើន និងលក្ខខណ្ឌនៅក្នុង កថាខណ្ឌ ៣.២.៥(ក)-(គ) នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩ ត្រូវបានបំពេញ។

## ទ្រព្យសកម្មហិរញ្ញវត្ថុបានផ្ទេរដែលមិនត្រូវបានទទួលស្គាល់ទាំងស្រុង

៤២ឃ អង្គភាពអាចមានទ្រព្យសកម្មហិរញ្ញវត្ថុបានផ្ទេរ ដោយការផ្ទេរមួយផ្នែក ឬទាំងអស់ នៃទ្រព្យសកម្មបានផ្ទេរដែលមិនមានគុណវុឌ្ឍ សម្រាប់ការមិនទទួលស្គាល់។ ដើម្បីឆ្លើយតបទៅនឹងកម្មវត្ថុបានកំណត់នៅក្នុង កថាខណ្ឌ ៤២ខ(ក), អង្គភាពត្រូវលាតត្រដាងនាកាលបរិច្ឆេទរាយកាណ៍និមួយៗ នូវថ្នាក់និមួយៗនៃទ្រព្យសកម្មបានផ្ទេរដែលមិនត្រូវបានមិនទទួលស្គាល់ទាំងស្រុង:

(ក) ចរិតលក្ខណៈរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

(ខ) ចរិតលក្ខណៈរបស់ហានិភ័យនិងផលចំណេញនៃកម្មសិទ្ធិភាព ដែលអង្គភាពត្រូវប្រឈម។

(គ) ការបរិយាយអំពីចរិតលក្ខណៈ នៃទំនាក់ទំនងរវាងទ្រព្យសកម្មបានផ្ទេរជាមួយនឹងបំណុលពាក់ពន្ធ័ ដោយរួមមានការដាក់កំហិត ដែលកើតចេញពីការផ្ទេរការប្រើប្រាស់ទ្រព្យសកម្មបានផ្ទេររបស់អង្គភាពរាយការណ៍។

(ឃ) នៅពេលដៃគូ (បណ្តាដៃគូ) នៃបំណុលពាក់ពន្ធ័មានឧបាស្រ័យតែចំពោះទ្រព្យសកម្មបានផ្ទេរ និងសមតុល្យសុទ្ធ (ភាពខុសគ្នារវាងតម្លៃសមស្របរបស់ទ្រព្យសកម្មបានផ្ទេរជាមួយនឹងបំណុលពាក់ពន្ធ័)។

(ង) នៅពេលដែលអង្គភាពបន្តទទួលស្គាល់ រាល់ទ្រព្យសកម្មបានផ្ទេរទាំងអស់, តម្លៃលើបញ្ជីរបស់ទ្រព្យសកម្មបានផ្ទេរ និងបំណុលពាក់ពន្ធ័ ទាំងអស់។

(ច) នៅពេលដែលអង្គភាពបន្តទទួលស្គាល់រាល់ទ្រព្យសកម្មបានផ្ទេរត្រឹមទំហំនៃភាពពាក់ពន្ធ័ជាបន្តរបស់ខ្លួន (មើលកថាខណ្ឌ ៣.២.៦(គ)(២) និងកថាខណ្ឌ ៣.២.១៦ នៃស្តង់ដារបាយការណ៍អន្តរជាតិ ៩), តម្លៃលើបញ្ជីសរុបរបស់ទ្រព្យ សកម្មដំបូងមុនពេលនៃការផ្ទេរ, តម្លៃលើបញ្ជីនៃទ្រព្យសកម្ម ដែលអង្គភាពបន្តទទួលស្គាល់,និងតម្លៃលើបញ្ជីរបស់បំណុលពាក់ពន្ធ័ ។

## ទ្រព្យសកម្មបានផ្ទេរដែលមិនទទួលស្គាល់ទាំងស្រុង

៤២ង ដើម្បីឆ្លើយតបទៅនឹងកម្មវត្ថុដូចបានកំណត់នៅក្នុង កថាខណ្ឌ ៤២ខ(ខ), នៅពេលអង្គភាព មិនទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទាំងស្រុង (មើល កថាខណ្ឌ ៣.២.៦(ក) និង (គ)(១) នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩) ប៉ុន្តែ មានការពាក់ពន្ធ័បន្តជាមួយ ទ្រព្យសកម្មទាំងនោះ, អង្គភាពត្រូវលាតត្រដាង, ក្នុងកម្រិតទាបបំផុត, សម្រាប់ប្រភេទនិមួយៗ នៃភាពពាក់ពន្ធបន្តនាកាលបរិច្ឆេទរាយកាណ៍និមួយៗ÷

(ក) តម្លៃលើបញ្ជីរបស់ទ្រព្យសកម្មនិងបំណុលដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព ហើយបង្ហាញភាពពាក់ពន្ធ័ជាបន្តរបស់អង្គភាពនៅក្នុងទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនទទួលស្គាល់, និងទីតាំងដែលតម្លៃលើបញ្ជីរបស់ទ្រព្យសកម្ម និងបំណុលទាំងនោះត្រូវបានទទួលស្គាល់។

(ខ) តម្លៃសមស្របនៃទ្រព្យសកម្មនិងបំណុលដែលតំណាងឲ្យភាពពាក់ពន្ធ័បន្តរបស់អង្គភាពនៅក្នុងទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនទទួលស្គាល់។

(គ) បរិមាណដែលជាតំណាងដ៏ល្អបំផុតនៃការប្រឈមទៅនឹងការខាតបង់ខ្ពស់បំផុតរបស់អង្គភាព ដែលកើតចេញពី ភាពជាប់ពាក់ពន្ធ័ជាបន្តនៅក្នុងទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនទទួលស្គាល់, និងព័ត៌មានដែលបង្ហាញពីការប្រឈមទៅ នឹងការខាតបង់ខ្ពស់បំផុតរបស់អង្គភាព។

(ឃ) លំហូរចេញនៃសាច់ប្រាក់ដែលមិនទាន់ធ្វើអប្បហារដែលនឹង ឬអាចត្រូវបានតម្រូវឲ្យទិញមកវិញនូវ ទ្រព្យសកម្មហិរញ្ញវត្ថុមិនបានទទួលស្គាល់ (ឧ.ថ្លៃខ្ពស់នៅក្នុងកិច្ចព្រមព្រៀងជម្រើសពិសេស) ឬបរិមាណទឹកប្រាក់ដែលត្រូវបង់ទៅ អ្នកទទួលការផ្ទេរពាក់ពន្ធ័នឹង ទ្រព្យសកម្មបានផ្ទេរ។

ប្រសិនបើលំហូរសាច់ប្រាក់មិនថេរ ដូចនេះ បរិមាណដែលបង្ហាញ ត្រូវពឹងផ្អែកលើលក្ខខណ្ឌដែលកើតឡើងនៅកាលបរិច្ឆេទរាយកាណ៍និមួយៗ។

(ង) ការវិភាគបក្កភាពនៃលំហូរសាច់ប្រាក់ដែលមិនទាន់ធ្វើអប្បហារ ដែលនឹងត្រូវឬអាចនឹងត្រូវបានតម្រូវឲ្យទិញមកវិញទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនទទួលស្គាល់ ឬបរិមាណទឹកប្រាក់ដែលត្រូវបង់ ទៅអ្នកទទួលការផ្ទេរពាក់ពន្ធ័នឹងទ្រព្យ សកម្មបានផ្ទេរ ដោយបង្ហាញបក្កភាពតាមមកិច្ចសន្យាដែលនៅសល់នៃភាពពាក់ពន្ធ័របស់អង្គភាព។

(ច) ព័ត៌មានគុណវុឌ្ឍដែលពន្យល់និងគាំទ្រការលាតត្រដាងមានលក្ខណៈជាបរិមាណវិស័យ ដែលបានតម្រូវនៅក្នុង (ក)-(ង)។

៤២ច អង្គភាពអាចច្របាច់បញ្ចូលព័ត៌មាន ដែលតម្រូវដោយកថាខណ្ឌ ៤២ ដាក់ទៅតាមទ្រព្យសកម្មជាក់លាក់មួយ ប្រសិនបើ អង្គភាពមានភាពពាក់ពន្ធ័បន្តច្រើនជាងមួយប្រភេទនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនទទួលស្គាល់ , និងរាយការណ៍វាតាមប្រភេទនិមួយៗនៃភាពពាក់ពន្ធ័។

៤២ឆ ជាបន្ថែម, អង្គភាពត្រូវលាតត្រដាងប្រភេទនិមួយៗ នៃភាពពាក់ពន្ធ័ៈ

(ក) ចំណេញ ឬខាត ដែលបានទទួលស្គាល់នៅកាលបរិច្ឆេទនៃការផ្ទេរទ្រព្យសកម្ម

(ខ) ចំណូលនិងចំណាយដែលបានទទួលស្គាល់ពីភាពពាក់ពន្ធ័នៅក្នុងទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនទទួលស្គាល់ (ឱ. បម្រែបម្រួលតម្លៃសមស្របនៅក្នុងឧបករណ៍ហិរញ្ញវត្ថុ) ទាំងក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ និង ការិយបរិច្ឆេទបន្តបន្ទាប់។

(គ) ប្រសិនបើ បរិមាណទឹកប្រាក់សរុបដែលបានមកពីសកម្មភាពនៃការផ្ទេរ(ដែលមានគុណវុឌ្ឍសម្រាប់ការមិនទទួលស្គាល់) នៅក្នុងការិយបរិច្ឆេទ

រាយការណ៍ មិនត្រូវបានបែងចែកយ៉ាងស្មើភាព ពេញមួយការិយបរិច្ឆេទរាយកាណ៍ (ឧ. ប្រសិនបើ ចំណែកដ៏ច្រើននៃបរិមាណសរុបនៃសកម្មភាពនៃការផ្ទេរកើតឡើងនៅក្នុងបិទបញ្ជីនៃការិយបរិច្ឆេទរាយការណ៍)៖

(១) នៅពេលដែលសកម្មភាពដ៏ធំនៃការផ្ទេរបានកើតឡើង នៅក្នុងការិយបរិច្ឆេទរាយការណ៍ (ឧ. ប្រាំថ្ងៃចុងក្រោយ មុនពេលបញ្ចប់ការិយបរិច្ឆេទរាយការណ៍),

(២) បរិមាណទឹកប្រាក់ (ឧ. ចំណេញ ឬខាតដែលពាក់ពន្ធ័) ដែលបានទទួលស្គាល់ណីសកម្មភាពនៃការផ្ទេរនៅក្នុងផ្នែកមួយនៃការិយ-បរិច្ឆេទរាយការណ៍, និង

(៣) បរិមាណទឹកប្រាក់សរុបបានមកពីសកម្មភាពនៃការផ្ទេរ នៅក្នុងផ្នែកមួយនៃការិយបរិច្ឆេទរាយការណ៍។

អង្គភាពត្រូវផ្តល់ព័ត៌មាននេះសម្រាប់ការិយបរិច្ឆេទនិមួយៗនៅក្នុងរបាយការណ៍លទ្ធផលសរុបដែលបានបង្ហាញ។

### ព័ត៌មានបំពេញបន្ថែម

**៤២ជ** អង្គភាពត្រូវលាតត្រដាងព័ត៌មានបន្ថែមដែលខ្លួនគិតថា មានភាពចាំបាច់ដើម្បីឆ្លើយតបទៅនឹងកម្មវត្ថុនៃការលាតត្រដាងនៅក្នុងកថាខណ្ឌ ៤២ខ។

## កាលបរិច្ឆេទចូលជាធរមាន និងកាលបរិច្ឆេទអន្តរកាល

៤៣ អង្គភាពត្រូវអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ សម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ឬ ក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០០៧។ ការអនុវត្តន៍មុនត្រូវបានលើកទឹកចិត្ត។ ប្រសិនបើអង្គភាព ត្រូវអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ សម្រាប់

ការិយបរិច្ឆេទ មុនការិយបរិច្ឆេទខាងលើ, អង្គភាព ត្រូវដាក់បង្ហាញនូវព្រឹត្តិការណ៍នោះ។

៤៤ ប្រសិនបើ អង្គភាព អនុវត្តនូវស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ សម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើមនៅថ្ងៃទី១ខែមករាឆ្នាំ២០០៦, អង្គភាពមិនចាំបាច់បង្ហាញព័ត៌មានប្រៀបធៀប សម្រាប់ការលាតត្រដាងព័ត៌មានដែលបានតម្រូវកថាខណ្ឌ ៣១-៤២ ស្តីអំពីចរិតលក្ខណៈ និងទំហំនៃហានិភ័យដែលកើតចេញពីឧបករណ៍ហិរញ្ញវត្ថុ។

៤៤ក ស្តង់ដាគណនេយ្យអន្តរជាតិ ១ (បានកែប្រែឡើងវិញក្នុង ឆ្នាំ២០០៧) បានកែប្រែបច្ចេកសព្ទ ដែលបានប្រើនៅក្នុង ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។ ជាការបន្ថែម ស្តង់ដាគណនេយ្យអន្តរជាតិ ១ បានកែប្រែកថាខណ្ឌ ២០, កថាខណ្ឌ ២១,កថាខណ្ឌ ២៣(គ) និង (ឃ), កថាខណ្ឌ ២៧(គ) និងកថាខណ្ឌ ខ៥ នៃឧបសម្ព័ន្ធ ខ។ អង្គភាពត្រូវអនុវត្តកំណែប្រែទាំងនោះសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ឬ ក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០០៩។ប្រសិនបើអង្គភាពអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិ១ (បានកែប្រែឡើងវិញក្នុងឆ្នាំ២០០៧) សម្រាប់ការិយបរិច្ឆេទដំបូង, កំណែប្រែនឹងត្រូវអនុវត្តចំពោះការិយបរិច្ឆេទនោះ។

៤៤ខ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៣ (បានកែប្រែនៅ ឆ្នាំ២០០៨) លុបចោលកថាខណ្ឌ៣(គ)។ អង្គភាពត្រូវអនុវត្ត កំណែប្រែនោះសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃទី១ ខែកក្កដា ឬក្រោយថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩។ ទោះជាយ៉ាងណា កំណែប្រែនោះមិនអនុវត្តចំពោះការតបសងជាយថាហេតុដែលកើតចេញពីសមាយោគអាជីវកម្ម ដែលនៅ

ក្នុងនោះកាលបរិច្ឆេទនៃការទិញកើតមុនការអនុវត្តន៍ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៣ (បានកែប្រែនៅឆ្នាំ២០០៨)។ ផ្ទុយទៅវិញ អង្គភាពត្រូវដាក់បញ្ចូលការតបសងនោះដោយយោងតាម កថាខណ្ឌ៦៥ក-៦៥ង នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៣ (បានកែប្រែនៅឆ្នាំ២០១០)។

៤៤គ អង្គភាពត្រូវអនុវត្តកំណែប្រែនៅក្នុងកថាខណ្ឌ ៣ សម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃទី១ ខែកក្កដា ឬក្រោយថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩។ ប្រសិនបើអង្គភាពអនុវត្ត *ឧបករណ៍ហិរញ្ញវត្ថុ សម្រាប់ដាក់លក់និងកាតព្វកិច្ច ដែលកើតចេញពីការជម្រះបញ្ជី* (កំណែប្រែចំពោះស្តង់ដាគណនេយ្យអន្តរជាតិ ៣២ និងស្តង់ដាគណនេយ្យអន្តរជាតិ ១), ដែលបានចេញផ្សាយនៅខែកុម្ភៈ ឆ្នាំ២០០៨, សម្រាប់ការិយបរិច្ឆេទមុន, កំណែប្រែនៅក្នុងកថាខណ្ឌ៣នឹងត្រូវអនុវត្ត សម្រាប់ការិយបរិច្ឆេទនោះ។

៤៤ឃ កថាខណ្ឌ ៣(ខ) ត្រូវបានកែប្រែ ដោយការធ្វើឱ្យប្រសើរឡើង ចំពោះស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយ នៅក្នុងខែឧសភា ឆ្នាំ២០០៨។ អង្គភាពត្រូវអនុវត្តកំណែប្រែសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ឬក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០០៩។ ការអនុវត្តន៍មុនត្រូវបានអនុញ្ញាត។ ប្រសិនបើ អង្គភាពអនុវត្តកំណែប្រែនោះសម្រាប់ការិយបរិច្ឆេទមុនការិយបរិច្ឆេទខាងលើ អង្គភាពត្រូវដាក់បង្ហាញនូវព្រឹត្តិការណ៍នោះ និងអនុវត្ត សម្រាប់ការិយបរិច្ឆេទនោះនូវកំណែប្រែចំពោះកថាខណ្ឌ ១ នៃស្តង់ដាគណនេយ្យអន្តរជាតិ ២៨, កថាខណ្ឌ ១ នៃស្តង់ដាគណនេយ្យអន្តរជាតិ ៣១, និង កថាខណ្ឌ ៤ នៃស្តង់ដាគណនេយ្យអន្តរជាតិ ៣២ ដែលបានចេញផ្សាយនៅ ខែឧសភា

ឆ្នាំ២០០៨។ អង្គភាពត្រូវបានអនុញ្ញាតឲ្យអនុវត្តមុននូវកំណែប្រែនោះផង ដែរ។

៤៤ង-៤៤ច [លុបចោល]

៤៤ឆ ការធ្វើឲ្យប្រសើរឡើង នូវការលាតត្រដាងព័ត៌ មានឧបករណ៍ហិរញ្ញវត្ថុ (កំណែប្រែចំពោះស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៧), ដែលបាន ចេញផ្សាយនៅខែមិនា ឆ្នាំ២០០៩, បានកែប្រែកថាខណ្ឌ ២៧, កថាខណ្ឌ ៣៩, កថាខណ្ឌ ខ១១, និងបានបន្ថែម កថាខណ្ឌ ២៧ក, កថាខណ្ឌ ២៧ខ ,កថាខណ្ឌ ខ១០ក និងកថាខណ្ឌ ខ១១ក-កថាខណ្ឌ ១១ច។ អង្គភាពត្រូវអនុវត្តកំណែប្រែសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើម នៅថ្ងៃទី១ ខែមករា ឬក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០០៩។ អង្គភាព មិនចាំ បាច់ផ្តល់ការលាតត្រដាងដែលបានតម្រូវដោយកំណែប្រែនោះ សម្រាប់ៈ

(ក) ការិយបរិច្ឆេទប្រចាំឆ្នាំឬចន្លោះពេល, ដោយមានទាំងដែលដាក់បញ្ចូល នូវរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ, ដែលបានបង្ហាញនៅក្នុងចុងការិយ-បរិច្ឆេទប្រៀបធៀបប្រចាំ ឆ្នាំ មុនថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០០៩, ឬ

(ខ) របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅដើមការិយបរិច្ឆេទប្រៀបធៀប ដំបូងបំផុត នៅមុនកាលបរិច្ឆេទ ថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០០៩។

ការអនុវត្តន៍មុនត្រូវបានអនុញ្ញាត។ ប្រសិនបើ អង្គភាពអនុវត្ត កំណែប្រែ នោះសម្រាប់ការិយបរិច្ឆេទ មុនការិយបរិច្ឆេទខាងលើ អង្គភាពត្រូវដាក់ បង្ហាញនូវព្រឹត្តិការណ៍នោះ *។

៤៤ជ [លុបចោល]

៤៤ឈ នៅពេលអង្គភាពអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ លើកដំបូង, អង្គភាពត្រូវដាក់បង្ហាញនូវថ្នាក់និមួយៗ នៃទ្រព្យសកម្មហិរញ្ញវត្ថុ នាកាលបរិច្ឆេទនៃការអនុវត្តដំបូងៈ

(ក) ក្រុមប្រភេទ នៃការវាស់វែងដើមដំបូងនិងតម្លៃលើបញ្ជី ដែលបានកំណត់ ដោយយោងតាមស្តង់ដាគណនេយ្យអន្តរជាតិ ៣៩

(ខ) ក្រុមប្រភេទនៃការវាស់វែងថ្មីនិងតម្លៃលើបញ្ជីដែលបានកំណត់ ដោយយោងតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩

(គ) បរិមាណទឹកប្រាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដែលពីមុនមកត្រូវបានកំណត់ ធ្វើការវាស់វែងតាមតម្លៃ លើបញ្ជីនៅក្នុងផ្នែករបាយការណ៍ចំណេញ ឬខាត ប៉ុន្តែ លែងមានការ កំណត់បែបនោះទៀតហើយ, ដោយការញែកចេញពីគ្នារវាងអ្វី ដែលបាន តម្រូវនៅក្នុងស្តង់ដា របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ដែលតម្រូវឲ្យ អង្គភាពធ្វើការបែងចែកថ្នាក់ឡើងវិញនូវទ្រព្យសកម្ម និងការតម្រូវ ដែល អង្គភាពជ្រើសរើសធ្វើការបែងចែកឡើងវិញនូវទ្រព្យសកម្ម។

អង្គភាពត្រូវបង្ហាញការលាតត្រដាងព័ត៌មានជាបរិមាណវិស័យនៅក្នុងទម្រង់ជាកូលោន ដរាបណា មានទម្រង់ផ្សេងទៀតដែលមានលក្ខណៈសមរម្យជាង។

៤៤ញ នៅពេលអង្គភាពអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ លើកដំបូង,អង្គភាពត្រូវដាក់បង្ហាញនូវព័ត៌មានដែលមានលក្ខណៈជាគុណវិស័យដើម្បីអាចឲ្យអ្នកប្រើយល់ៈ

(ក)របៀបអនុវត្តនូវការតម្រូវនៃការធ្វើចំណាត់ថ្នាក់ឡើងវិញនៅក្នុងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ដែលការ

ធ្វើចំណាត់ថ្នាក់របស់វា បានផ្លាស់ប្តូរ ដោយសារតែការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩។

(ខ) ហេតុផលនៃការកំណត់ និងមិនកំណត់ជាទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ដែលបានវាស់វែង តាមតម្លៃសមស្រប នៅក្នុងផ្នែករបាយការណ៍ចំណេញ ឬខាត។

៤៤ត កថាខណ្ឌ ៤៤ខ ត្រូវបានកែប្រែឡើងវិញដោយ *ការធ្វើឲ្យប្រសើរឡើងចំពោះស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ* ដែលបានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១០។ អង្គភាពត្រូវអនុវត្តកំណែប្រែនោះ សម្រាប់ការិយ-បរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃទី១ ខែកក្កដា ឬក្រោយថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩។ការអនុត្តន៍មុនត្រូវបានអនុញ្ញាត។

៤៤ថ *ការធ្វើឲ្យប្រសើរឡើងចំពោះស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ* ដែលបានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១០ បានបន្ថែមកថាខណ្ឌ ៣២ក និងកែប្រែកថាខណ្ឌ ៣៤ និងកថាខណ្ឌ ៣៦-៣៨។ អង្គភាពត្រូវអនុវត្តកំណែប្រែទាំងនោះ សម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ឬក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០១១។ ការអនុត្តន៍មុនត្រូវបានអនុញ្ញាត។ ប្រសិនបើ អង្គភាពអនុវត្តកំណែប្រែនោះសម្រាប់ការិយ-បរិច្ឆេទមុនការិយបរិច្ឆេទខាងលើ អង្គភាពត្រូវដាក់បង្ហាញនូវព្រឹត្តិការណ៍នោះ ។

៤៤ទ *ការលាតត្រដាងព័ត៌មានការផ្ទេរទ្រព្យសកម្មហិរញ្ញវត្ថុ* (កំណែប្រែចំពោះស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៧), ដែលបានចេញផ្សាយនៅខែតុលា ឆ្នាំ២០១០, បានលុបចោលកថាខណ្ឌ ១៣ និងបន្ថែម កថាខណ្ឌ ៤២ក-កថាខណ្ឌ៤២ជ និងកថាខណ្ឌខ២៩-កថាខណ្ឌខ៣៩។ អង្គភាព

ត្រូវអនុវត្តកំណែប្រែទាំងនោះសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើម នៅថ្ងៃទី១ ខែកក្កដា ឬក្រោយថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១១។ ការអនុវត្តន៍មុន ត្រូវបានអនុញ្ញាត។ ប្រសិនបើ អង្គភាព អនុវត្តកំណែប្រែនោះ សម្រាប់ការិយបរិច្ឆេទ មុនការិយបរិច្ឆេទខាងលើ អង្គភាព ត្រូវដាក់បង្ហាញនូវព្រឹត្តិការណ៍នោះ។ អង្គភាពមិនចាំបាច់ផ្តល់ការលាតត្រដាងដែលបានតម្រូវដោយកំណែប្រែទាំងនោះសម្រាប់ការិយបរិច្ឆេទណា មួយដែលបានបង្ហាញ ដែលចាប់ផ្តើមមុនកាលបរិច្ឆេទនៃការអនុវត្តន៍ដំបូងនៃកំណែប្រែនោះ។

៤៤ធ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩, ដែលបានចេញផ្សាយនៅខែតុលា ឆ្នាំ២០១០, បានកែប្រែកកថាខណ្ឌ ២-៥,កថាខណ្ឌ ៨-១០, កថាខណ្ឌ១១, កថាខណ្ឌ១៤, កថាខណ្ឌ២០, កថាខណ្ឌ២៨, កថាខណ្ឌ៣០ និងកថាខណ្ឌ ៤២គ-៤២ង,

ឧបសម្ពន្ធ័ ក និងកថាខណ្ឌ ខ១, កថាខណ្ឌ ខ៥, កថាខណ្ឌ ខ១០(ក), កថាខណ្ឌ ខ២២ និងកថាខណ្ឌ ខ២៧, បានបន្ថែម កថាខណ្ឌ ១០ក, កថាខណ្ឌ ១១ក, កថាខណ្ឌ ១១ខ, កថាខណ្ឌ ១២ខ-កថាខណ្ឌ ១២ឃ, កថាខណ្ឌ២០ក, កថាខណ្ឌ៤៤ញ, និងកថាខណ្ឌ ៤៤ត, និងលុបចោលកថាខណ្ឌ១២, កថាខណ្ឌ១២ក, កថាខណ្ឌ២៩(ខ),កថាខណ្ឌ៤៤ង, កថាខណ្ឌ៤៤ច, កថាខណ្ឌ៤៤ជ និងកថាខណ្ឌខ៤ និងឧបសម្ពន្ធ័ ឃ។ អង្គភាព ត្រូវអនុវត្តកំណែប្រែទាំងនោះ នៅពេលខ្លួន អនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ ដែលបានចេញផ្សាយ នៅខែតុលា ឆ្នាំ២០១០។

| | |
|---|---|
| ៤៥ | ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ ជំនួសស្តង់ដាគណនេយ្យ អន្តរជាតិ ៣០ *ការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារនិងស្ថាប័នហិរញ្ញវត្ថុប្រហាក់ប្រហែល*។ |

## ឧបសម្ព័ន្ធ ក
## និយមន័យនៃពាក្យ
## ឧបសម្ព័ន្ធនេះគឺជាផ្នែកមួយនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តជាតិ.

| | |
|---|---|
| ហានិភ័យឥណទាន | ហានិភ័យដែលភាគីមួយពាក់ពន្ធ័នឹងឧបករណ៍ហិរញ្ញវត្ថុនឹងបណ្តាលឲ្យ មានការខាតបង់ផ្នែកហិរញ្ញវត្ថុ ចំពោះភាគីមួយទៀតដោយសារមិនបានគោរពតាមកាតព្វកិច្ច។ |
| ហានិភ័យរូបិយវត្ថុ | ហានិភ័យដែលតម្លៃសមស្រប ឬលំហូរសាច់ប្រាក់ នាពេលអនាគត របស់ឧបករណ៍ហិរញ្ញវត្ថុនឹងមានការប្រែប្រួល ឡើងចុះដោយសារតែការប្រែប្រួលអត្រាប្តូរប្រាក់បរទេស។ |
| ហានិភ័យអត្រាការប្រាក់ | ហានិភ័យដែលតម្លៃសមស្រប ឬលំហូរសាច់ប្រាក់ នាពេលអនាគត របស់ឧបករណ៍ហិរញ្ញវត្ថុនឹងមានការប្រែប្រួលឡើងចុះដោយសារតែការប្រែប្រួលអត្រាការប្រាក់របស់ទីផ្សារ។ |
| ហានិភ័យសន្ទនីយភាព | ហានិភ័យដែលអង្គភាពនឹងជួបប្រទះការលំបាកនៅក្នុង |

ការទូទាត់បំណុលដែលពាក់ពន្ធ័ជាមួយបំណុលហិរញ្ញវត្ថុ ដែលត្រូវទូទាត់ជាសាច់ប្រាក់ ឬទ្រព្យសកម្ម ហិរញ្ញវត្ថុផ្សេង។

| | |
|---|---|
| បំណុលប្រាក់កម្ចី | បំណុលប្រាក់កម្ចី គឺជាបំណុលហិរញ្ញវត្ថុ, បំណុលរយៈពេលខ្លីពាក់ពន្ធ័នឹង សកម្មភាពអាជីវកម្មតាមលក្ខខណ្ឌឥណទានធម្មតា។ |
| ហានិភ័យទីផ្សារ | ហានិភ័យដែលតម្លៃសមស្រប ឬលំហូរសាច់ប្រាក់ នាពេលអនាគត របស់ឧបករណ៍ហិរញ្ញវត្ថុនឹងមានការប្រែប្រួលឡើងចុះដោយសារតែការប្រែប្រួលថ្លៃរបស់ទីផ្សារ។ ហានិភ័យទីផ្សាររួមមានបីប្រភេទៈ ហានិភ័យរូបិយវត្ថុ, ហានិភ័យអត្រាការប្រាក់, និង ហានិភ័យថ្លៃផ្សេងៗ។ |
| ហានិភ័យថ្លៃផ្សេងៗ | ហានិភ័យដែលតម្លៃសមស្រប ឬលំហូរសាច់ប្រាក់ នាពេលអនាគត របស់ឧបករណ៍ហិរញ្ញវត្ថុនឹងមានការប្រែប្រួលឡើងចុះដោយសារតែការប្រែប្រួលថ្លៃរបស់ទីផ្សារ (ដែលមិនកើតឡើង ដោយសារតែហានិភ័យអត្រាការប្រាក់ ឬហានិភ័យរូបិយវត្ថុ), ថាតើការប្រែប្រួលទាំងនោះបណ្តាលមកពីកត្តាដ៏ជាក់លាក់ចំពោះឧបករណ៍ហិរញ្ញវត្ថុនិមួយៗ ឬអ្នកបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុ, ឬកត្តាដែលមានផលប៉ះពាល់ ដល់គ្រប់ឧបករណ៍ ហិរញ្ញវត្ថុស្រដៀងគ្នាដែលបានជួញដូរនៅក្នុងទីផ្សារ។ |

| | |
|---|---|
| ហួសកំណត់សង | ទ្រព្យសកម្មហិរញ្ញវត្ថុដែលហួសកំណត់សង នៅពេលដៃគូរមួយខកខានមិនបានសងនៅពេលវាដល់ កំណត់សងតាមកិច្ចសន្យា។ |

ពាក្យខាងក្រោមត្រូវបានកំណត់អត្ថន័យនៅក្នុងកថាខណ្ឌ ១១ នៃស្តង់ដាគណនេយ្យអន្តរជាតិ ៣២, កថាខណ្ឌ៩នៃស្តង់ដាគណនេយ្យអន្តរជាតិ ៣៩, ឧបសម្ព័ន្ធ **ក** នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ និងត្រូវបានប្រើនៅក្នុងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ជាមួយនឹងអត្ថន័យបានបញ្ជាក់ នៅក្នុងស្តង់ដាគណនេយ្យអន្តរជាតិ ៣២, ស្តង់ដាគណនេយ្យអន្តរជាតិ ៣៩, និងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩។

- តម្លៃបានដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុ
- ការមិនទទួលស្គាល់
- និស្សន្ទ
- ឧបករណ៍ហិរញ្ញវត្ថុកម្មសិទ្ធិ
- តម្លៃសមស្រប
- ទ្រព្យសកម្មហិរញ្ញវត្ថុ
- កិច្ចសន្យាធានាហិរញ្ញវត្ថុ
- ឧបករណ៍ហិរញ្ញវត្ថុ
- បំណុលហិរញ្ញវត្ថុ
- បំណុលហិរញ្ញវត្ថុ តាមតម្លៃសមស្រប នៅក្នុងផ្នែករបាយការណ៍ចំណេញខាត

- ប្រតិបត្តិការព្យាករណ៍
- ឧបករណ៍ទប់ស្កាត់ហានិភ័យ
- រក្សាទុកសម្រាប់ការជួញដូរ
- កាលបរិច្ឆេទធ្វើចំណាត់ថ្នាក់ឡើងវិញ
- ការទិញឬលក់តាមរបៀបធម្មតា

## ឧបសម្ព័ន្ធ៧ ខ

## សេចក្តីណែនាំសម្រាប់ការអនុវត្តន៍

## ឧបសម្ព័ន្ធនេះគឺជាផ្នែកមួយនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តជាតិ.

## ថ្នាក់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងកម្រិតនៃការលាតត្រដាងព័ត៌មាន (កថាខណ្ឌ ៦)

១១ កថាខណ្ឌ ៦ តម្រូវឱ្យអង្គភាពដាក់ជាក្រុម នូវឧបករណ៍ហិរញ្ញវត្ថុទៅជាថ្នាក់ៗ ដែលសមស្របតាមចរិតលក្ខណៈ នៃព័ត៌មាន ដែលបានបង្ហាញ និងពិចារណាចរិតលក្ខណៈ នៃឧបករណ៍ហិរញ្ញវត្ថុទាំងនោះផង។ បណ្តាថ្នាក់ដែលបានរៀបរាប់ នៅក្នុងកថាខណ្ឌ ៦ ត្រូវបានកំណត់ដោយអង្គភាព និងដែលខុសគ្នាពីប្រភេទនៃឧបករណ៍ហិរញ្ញវត្ថុដែលបានបញ្ជាក់ នៅក្នុងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ (ដែលកំណត់អំពីរបៀបនៃការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ និងការទទួលស្គាល់ការប្រែប្រួល តម្លៃសមស្រប)។

១២ នៅក្នុងការកំណត់ថ្នាក់របស់ឧបករណ៍ហិរញ្ញវត្ថុជាកម្រិតអប្បបរិមាអង្គភាពត្រូវៈ

(ក) ញែកឱ្យដាច់ពីគ្នានូវឧបករណ៍ហិរញ្ញវត្ថុ ដែលវាស់វែងតាមតម្លៃដករំលស់និងឧបករណ៍ហិរញ្ញវត្ថុដែលវាស់វែងតាម តម្លៃសមស្រប។

(ខ) ដាក់ដាច់ដោយឡែកពីគេនូវឧបករណ៍ហិរញ្ញវត្ថុណា ដែលមិនស្ថិតនៅក្នុងក្របខណ្ឌនៃស្តង់ដាបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ។

ខ៣ យោងតាមកាលៈទេសៈរបស់ខ្លួន អង្គភាពត្រូវសម្រេច អំពីកម្រិតនៃសេចក្តីលំអិតដែលត្រូវផ្តល់ឲ្យដើម្បីបំពេញតាម ការតម្រូវនៃស្តង់ដាបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ, អំពីកម្រិតនៃការបញ្ជាក់ ដែលអង្គភាពធ្វើតាមទិដ្ឋភាពផ្សេងៗ នៃឧបករណ៍ហិរញ្ញវត្ថុ និងរបៀបនៃការបូកបញ្ចូលគ្នានូវព័ត៌មានដើម្បីបង្ហាញទិដ្ឋភាពរួមដោយមិនចាំបាច់បញ្ចូលគ្នានូវ ព័ត៌មានដែលមានចរិតលក្ខណៈផ្សេងគ្នា។ វាជាការចាំបាច់ ដែលត្រូវធ្វើឲ្យមានតុល្យភាពមួយ រវាងការផ្ទុកព័ត៌មានច្រើនហួសហេតុ ដោយការបង្ហាញសេចក្តីលំអិតពេក ដែលមិនអាចជួយដល់អ្នកប្រើរបាយការណ៍ហិរញ្ញវត្ថុជាមួយនឹងភាពពិបាកយល់របស់ព័ត៌មានដែលមានសារៈសំខាន់ ដែលជាលទ្ធផល នៃការប្រមូលផ្តុំព័ត៌មានច្រើនលើសលុបពេក។ ជាឧទាហរណ៍ អង្គភាពមិនត្រូវធ្វើឲ្យបាត់នូវព័ត៌មានដែលសំខាន់ដោយការរួមបញ្ចូលព័ត៌មានទៅក្នុងសេចក្តីលំអិត ដែលមិនមានសារៈសំខាន់ដែកមានច្រើនស្អេកស្កាស់។ ស្រដៀងគ្នានេះដែរ អង្គភាពមិនត្រូវលាតត្រដាងព័ត៌មានដែលមានលក្ខណៈប្រមូលផ្តុំពេកដែលនឹងធ្វើឲ្យបាត់ភាពខុសគ្នាសំខាន់ៗ រវាងប្រតិបត្តិការនិមួយនិងហានិភ័យដែលពាក់ពន្ធ័។

## សារៈសំខាន់នៃឧបករណ៍ហិរញ្ញវត្ថុសម្រាប់ស្ថានភាពហិរញ្ញវត្ថុនិងលទ្ធផលហិរញ្ញវត្ថុ

ខ៤ [ លុបចោល ]

៣៥ កថាខណ្ឌ ២១ តម្រូវនូវការលាតត្រដាងមូលដ្ឋាន នៃការវាស់វែង ដែលបានប្រើនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងបណ្ដាគោលនយោបាយគណនេយ្យផ្សេងៗដែលបានប្រើ ដែលមានភាពពាក់ពន្ធ័នឹងការយល់ដឹងអំពី របាយការណ៍ហិរញ្ញវត្ថុ។ សម្រាប់ឧបករណ៍ហិរញ្ញវត្ថុ, ការលាតត្រដាងព័ត៌មានអាចរួមមានៈ

(ក) សម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ដែលបានកំណត់តាមតម្លៃសមស្របនៅក្នុងផ្នែករបាយការណ៍ចំណេញ ឬខាតៈ

(១) ចរិតលក្ខណៈរបស់បំណុលហិរញ្ញវត្ថុ ដែលអង្គភាព បានកំណត់តាមតម្លៃសមស្របនៅក្នុងផ្នែករបាយការណ៍ ចំណេញឬខាត

(២) លក្ខណៈវិនិច្ឆ័យសម្រាប់ការកំណត់បំណុលហិរញ្ញវត្ថុ ឱ្យទៅជាបែបនោះ នៅខណៈពេលនៃការទទួលស្គាល់ លើកដំបូង និង

(៣) វិធីដែលអង្គភាពបំពេញបាន តាមលក្ខខណ្ឌនានា នៅក្នុងកថាខណ្ឌ ៤.២.២ នៃស្តង់ដាគណនេយ្យអន្តរជាតិ ៩ សម្រាប់ការ កំណត់បែបនោះ។

(កក) សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកំណត់ថាបានវាស់វែង តាមតម្លៃសមស្របនៅក្នុងផ្នែករបាយការណ៍ចំណេញ ឬខាតៈ

(១)ចរិតលក្ខណៈរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលអង្គភាពបាន កំណត់ថាបានវាស់វែងតាមតម្លៃសមស្រប នៅក្នុងផ្នែករបាយការណ៍ ចំណេញ ឬខាត និង

(២)វិធីដែលអង្គភាពបំពេញបានតាមលក្ខខណ្ឌនានា នៅក្នុង កថាខណ្ឌ ៤.១.៥ នៃស្តង់ដាគណនេយ្យអន្តរជាតិ ៩ សម្រាប់ការ កំណត់បែបនោះ។

(ខ) [លុបចោល]

(គ) ថាតើការការទិញនិងការលក់តាមវិធីធម្មតារបស់ទ្រព្យសកម្មហិរញ្ញ-វត្ថុ ត្រូវបានរាប់បញ្ចូលនាកាលបរិច្ឆេទជួញដូរ ឬនាកាលបរិច្ឆេទ ទូទាត់ (មើលកថាខណ្ឌ ៣.១.២ នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុ អន្តរជាតិ ៩)។

(ឃ) នៅពេលដែលគណនីវិភាជន៍ត្រូវបានប្រើ ដើម្បីតម្លៃលើបញ្ជីរបស់ ទ្រព្យសកម្មហិរញ្ញវត្ថុដែលទទួលរងការថយតម្លៃ ដោយការខាតបង់ ខាងឥណទានៈ

(១)លក្ខណៈវិនិច្ឆ័យសម្រាប់ការកំណត់តម្លៃលើបញ្ជីរបស់ទ្រព្យសកម្ម ហិរញ្ញវត្ថុដែលទទួលរងការថយតម្លៃ ត្រូវបានបន្ថយដោយផ្ទាល់ (ឬ នៅក្នុងករណីនៃការចុះបញ្ច្រាសនៃការលុបចេញពីបញ្ជី, បានធ្វើឲ្យ កើនឡើងដោយផ្ទាល់) និងនៅពេលណាដែលគណនីវិភាជន៍ត្រូវបាន ប្រើ និង

(២) លក្ខណៈវិនិច្ឆ័យសម្រាប់ការលុបចោលបរិមាណដែលបានដាក់ បញ្ចូលទៅក្នុងគណនីវិភាជន៍ធៀបនឹងតម្លៃ លើបញ្ជីរបស់ទ្រព្យសកម្ម ហិរញ្ញវត្ថុដែលទទួលរងការថយចុះតម្លៃ(មើលកថាខណ្ឌ១៦)

(ង) របៀបនៃការកំណត់ចំណេញសុទ្ធឬខាតសុទ្ធតាមប្រភេទនីមួយៗ នៃឧបករណ៍ហិរញ្ញវត្ថុ (មើលកថាខណ្ឌ២០(ក)) ឧទាហរណ៍ ថាតើចំណេញសុទ្ធឬខាតសុទ្ធលើទ្រព្យសកម្មទាំងនោះតាមតម្លៃសមស្រប នៅក្នុងផ្នែករបាយការណ៍ចំណេញ ឬខាត រួមបញ្ចូលនូវការប្រាក់ ឬភាគលាភឬទេ។

(ច) លក្ខណៈវិនិច្ឆ័យដែលអង្គភាពប្រើដើម្បីកំណត់ថាមានភស្តុតាងច្បាស់លាស់ដែលការខាតបង់ដោយការធ្លាក់ចុះតម្លៃបានកើតឡើង (មើលកថាខណ្ឌ២០(ង))

(ឆ) ពេលវេលា ដែលលក្ខខណ្ឌ នៃទ្រព្យសកម្មហិរញ្ញវត្ថុ នឹងត្រូវហួសកំណត់សងឬបានថយចុះតម្លៃ ត្រូវបានចរចារឡើងវិញ, គោលនយោបាយគណនេយ្យសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលជាកម្មវត្ថុនៃលក្ខខណ្ឌដែលបានចរចារ ឡើងវិញ (មើល កថាខណ្ឌ៣៦(ឃ))

កថាខណ្ឌ ១២២ នៃស្តង់ដា គណនេយ្យអន្តរជាតិ ១ (បានកែប្រែនៅឆ្នាំ២០០៧) ក៏តម្រូវឲ្យអង្គភាពត្រូវលាតត្រដាង, ដោយសេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យ ឬកំណត់សម្គាល់សំខាន់ៗ, ការវិនិច្ឆ័យនានា, ការប៉ាន់ស្មានសំខាន់នានា, ដែលអ្នកគ្រប់គ្រងបានធ្វើនៅក្នុងដំណើរការអនុវត្តគោលនយោបាយ គណនេយ្យ និងដែលមានផលប៉ះពាល់លើបរិមាណ ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ចរិតលក្ខណៈនិងទំហំនៃហានិភ័យដែលកើតចេញពីឧបករណ៍ហិរញ្ញវត្ថុ (កថាខណ្ឌ៣១-៤២)

---

៣៦ ការលាតត្រដាងដែលបានតម្រូវដោយកថាខណ្ឌ ៣១-៤២ នឹងត្រូវបានផ្តល់ឲ្យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬដាក់ចូល ក្នុងសេចក្តីយោងនឹង

យោងផ្សេងទៀតចេញពីរបាយការណ៍ហិរញ្ញវត្ថុទៅនឹងរបាយការណ៍ផ្សេងទៀតដូចជាសេចក្តីឬអត្ថបទវិចារណកថារបស់អ្នកគ្រប់គ្រងឬរបាយការណ៍អំពីហានិភ័យដែលអាចរកបានសម្រាប់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងពេលវេលាតែមួយ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុតែមួយ និងនៅពេលវេលាដូចគ្នា។ ដោយគ្មានព័ត៌មានដែលដាក់ចូលនៅក្នុងសេចក្តីយោងនឹងសេចក្តីយោងផ្សេងទៀត របាយការណ៍ហិរញ្ញវត្ថុនោះមិនពេញលេញឡើយ។

ការលាតត្រដាងព័ត៌មានជាលក្ខណៈបរិមាណវិស័យ (កថាខណ្ឌ ៣៤)

១៧ កថាខណ្ឌ ៣៤(ក) តម្រូវឱ្យមានការលាតត្រដាង ដោយសង្ខេបនូវទិន្នន័យដែលមានលក្ខណៈជាបរិមាណវិស័យអំពីការ ប្រឈមរបស់អង្គភាពទៅនឹងហានិភ័យ ដោយផ្អែកលើព័ត៌មាន ដែលបាផ្តល់ឱ្យពីផ្ទៃក្នុងទៅឱ្យបុគ្គលសំខាន់ៗរបស់អង្គភាព។ នៅពេលដែលអង្គភាព ប្រើវិធីសាស្រ្តជាច្រើនផ្សេងៗ គ្នាដើម្បីគ្រប់គ្រងការប្រឈមនឹងហានិភ័យ អង្គភាពត្រូវលាតត្រដាងព័ត៌មានដោយប្រើវិធីសាស្រ្តមួយឬច្រើនដែលផ្តល់នូវព័ត៌មានដែលពាក់ពន្ធ័និងអាចជឿទុកចិត្តបានបំផុត។ ស្តង់ដាគណនេយ្យអន្តរជាតិ៨ *គោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរនៅក្នុងការប៉ាន់ស្មានគណនេយ្យនិងលំអៀង*លាតត្រដាងនូវភាពជាប់បាក់ពន្ធ័និងភាពអាចជឿទុកចិត្តបាន។

១៨ កថាខណ្ឌ ៣៤(គ) តម្រូវឱ្យលាតរត្រដាងនូវបណ្តុំនៃហានិភ័យ ដែលកើតឡើងពីឧបករណ៍ហិរញ្ញវត្ថុដែលមានចរិតលក្ខណៈ ស្រដៀងគ្នា និងទទួលរងស្រដៀងគ្នា ដោយការប្រែប្រួល នៅក្នុងសេដ្ឋកិច្ចនិងលក្ខខណ្ឌនានា។ អត្តសញ្ញាណ នៃបណ្តុំហានិភ័យតម្រូវឱ្យ ការវិនិច្ឆ័យត្រូវរាប់បញ្ចូលនូវ

កាលៈទេសៈនានារបស់អង្គភាព។ ការលាតត្រដាងបណ្ដុំ នៃហានិភ័យត្រូវដាក់បញ្ចូលនូវៈ

(ក) ការបរិយាយអំពីរបៀប ដែលអ្នកគ្រប់គ្រងកំណត់អំពី បណ្ដុំរបស់ហានិភ័យ

(ខ) ការបរិយាយអំពីចរិតលក្ខណៈរួមដែលកំណត់បានអត្តសញ្ញាណរបស់បណ្ដុំនិមួយៗ (ឧ. ភាពជាដៃគូ, តំបន់ភូមិសាស្ត្រ, រូបិយវត្ថុ ឬទីផ្សារ) និង

(គ) បរិមាណនៃការប្រឈមនឹងហានិភ័យដែលពាក់ពន្ធ័ជាមួយឧបករណ៍ហិរញ្ញវត្ថុទាំងអស់ដែលមានចរិតលក្ខណៈរួមនោះ។

## ការប្រឈមហានិភ័យឥណទានអតិបរមា (កថាខណ្ឌ ៣៦ ៩(ក))

ខ៩ កថាខណ្ឌ ៣៦(ក) តម្រូវឲ្យមានការលាតត្រដាងបរិមាណដែលតំណាងយ៉ាងល្អបំផុត នូវការប្រឈមជាអតិបរមា ទៅនឹងហានិភ័យឥណទាន។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ជាធម្មតា បរិមាណនេះគឺជាតម្លៃលើបញ្ជីដុលដោយដកចេញៈ

(ក) បរិមាណដែលកាត់កងដោយយោងតាមស្តង់ដាគណនេយ្យអន្តរជាតិ ៣២ និង

(ខ)ការខាតបង់ដោយការធ្លាក់ចុះតម្លៃដែលបានទទួលស្គាល់ ដោយយោងតាមស្តង់ដាគណនេយ្យអន្តរជាតិ ៣៩។

ខ១០ សកម្មភាព ដែលបង្កើនហានិភ័យឥណទាន និងការប្រឈមជាអតិបរមាដែលពាក់ពន្ធ័ទៅនឹងហានិភ័យឥណទាន ដែលរួមមាន ប៉ុន្តែមិនកម្រិតត្រឹមៈ

(ក)កម្ចីជាអំណោយចំពោះអតិថិជននិងការដាក់ប្រាក់បញ្ញើជាមួយអង្គភាពផ្សេងៗ។ នៅក្នុងករណីនេះ ការប្រឈមជា អតិបរមាចំពោះហានិភ័យឥណទានគឺជាតម្លៃលើបញ្ជីរបស់ទ្រព្យសកម្មហិរញ្ញវត្ថុដែលពាក់ពន្ធ័។

(ខ)ការធ្វើកិច្ចសន្យានិស្សន្ទ, ឧ. កុងត្រាអត្រាប្តូរប្រាក់, កិច្ចសន្យាដោះដូរអត្រាការប្រាក់និងនិស្សន្ទឥណទាន។នៅពេលដែលទ្រព្យសកម្ម ត្រូវបានវាស់វែងតាមតម្លៃសមស្រប, ការប្រឈមជាអតិបរមាទៅនឹង ហានិភ័យឥណទាននៅចុងកាល បរិច្ឆេទរាយការណ៍នឹងស្មើនឹងតម្លៃលើបញ្ជីនោះ។

(គ) ការផ្តល់អំណោយជាការធានាហិរញ្ញវត្ថុ។នៅក្នុងករណីនេះការប្រឈមជាអតិបរិមាចំពោះហានិភ័យឥណទានគឺជា បរិមាណជាអតិបរមា ដែលអង្គភាព អាចត្រូវបង់ ប្រសិនបើការធានាត្រូវបានតម្រូវ ដែលអាចមានតម្លៃច្រើនជាងបរិមាណដែលបានទទួលស្គាល់ជាបំណុល។

(ឃ) ការតាំងចិត្តសងប្រាក់កម្ចីដែលមិនអាចទទួលបានមកវិញតាមអាយុកាលរបស់មធ្យោបាយសម្រួលប្រាក់កម្ចី ឬអាចទទួលបានមកវិញតែចំពោះការប្រែប្រួលដ៏អាក្រក់ជាកដុំកំភួនប៉ុណ្ណោះ។ ប្រសិនបើ អ្នកបោះផ្សាយមិនអាចទូទាត់ ការតាំងចិត្តសងប្រាក់កម្ចី ជាសាច់ប្រាក់សុទ្ធ ឬដោយឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត, ការប្រឈមហានិភ័យឥណទានអតិបរមាគឺជាបរិមាណគ្រប់ចំនួននៃការតាំងចិត្តសង។ នេះក៏ដោយសារតែ វាមិនប្រាកដថាតើបរិមាណនៃផ្នែកដែលមិន បានដកយកអាចដកបាន នាពេលអនាគតឬទេ។ បរិមាណនេះអាចមានចំនួនច្រើនជាងបរិមាណ ដែលបានទទួលស្គាល់ ជាបំណុល។

**ការលាតត្រដាងព័ត៌មានអំពីហានិភ័យសន្ទនីយភាពបែបជាលក្ខណៈវិស័យ (កថាខណ្ឌ៣៤(ក) និង ៣៩(ក)និង(ខ))**

១១០ក យោងតាមកថាខណ្ឌ ៣៤(ក) អង្គភាពលាតត្រដាង ដោយសង្ខេបនូវទិន្នន័យបែបបរិមាណវិស័យ អំពីការប្រឈមរបស់ខ្លួនទៅនឹង ហានិភ័យឥណទានដោយផ្អែកលើព័ត៌មានដែលបានផ្តល់ដោយផ្ទៃក្នុងចំពោះបុគ្គលសំខាន់។ អង្គភាពត្រូវ ពន្យល់របៀប ដែលទិន្នន័យត្រូវបានកំណត់។ ប្រសិនបើលំហូរចេញនៃសាច់ប្រាក់ (ឬ ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេង) ត្រូវបានបញ្ចូលទៅក្នុងទិន្នន័យទាំងនោះ អាចៈ

(ក) កើតឡើងយ៉ាងច្បាស់លាស់មុនពេលដែលទិន្នន័យត្រូវបានបង្ហាញ

(ខ) បរិមាណដែលខុសគ្នាយ៉ាងខ្លាំងពីបរិមាណដែលបានបង្ហាញ នៅក្នុងទិន្នន័យ (ឱ. សម្រាប់និស្សន្ទដែលត្រូវបានដាក់ បញ្ចូលទៅក្នុងទិន្នន័យដោយផ្អែកលើមូលដ្ឋាននៃការទូទាត់សុទ្ធ ប៉ុន្តែ ដែលដៃគូរមានជម្រើសពិសេសដើម្បីទាមទារនូវការទូទាត់ដុល), អង្គភាពត្រូវបង្ហាញអំពីព្រឹត្តិការណ៍នោះ និងផ្តល់នូវព័ត៌មានបែបបរិមាណវិស័យ ដែលអាចឲ្យអ្នកប្រើរបាយ-ការណ៍ហិរញ្ញវត្ថុវាយតម្លៃបានពីទំហំនៃហានិភ័យនេះ ដរាបណាព័ត៌មាននោះត្រូវបានដាក់បញ្ចូលទក្នុងការវិភាគបក្កភាពតាមកិច្ចសន្យា ដែលបានតម្រូវដោយកថាខណ្ឌ៣៩(ក) ឬ(ខ)។

១១១ ក្នុងការរៀបចំការវិភាគបក្កភាពដែលបានតម្រូវដោយ កថាខណ្ឌ ៣៩(ក) និង (ខ), អង្គភាពប្រើការវិនិច្ឆ័យដើម្បីកំណត់ ចំនួនក្រុមនៃពេលវេលាសមរម្យ។ ឧទាហរណ៍ អង្គភាព អាចកំណត់ក្រុមនៃពេលវេលាខាងក្រោមថាមានភាពសមរម្យៈ

(ក) មិនយឺតជាងមួយខែ

(ខ) មិនយឺតជាងមួយខែ និងមិនមិនយឺតជាងបីខែ

(គ) មិនយឺតជាងបីខែ និងមិនយឺតជាងមួយឆ្នាំ និង

(ឃ) មិនយឺតជាងមួយឆ្នាំនិងមិនយឺតជាងប្រាំឆ្នាំ។

ខ១១ក ដើម្បីអនុលោមតាម កថាខណ្ឌ ៣៩(ក) និង(ខ) អង្គភាពមិនត្រូវបែងចែកដាច់ពីគ្នានូវ និស្សន្ទបង្កប់ពីឧបករណ៍ហិរញ្ញវត្ថុ ដែលមានលក្ខណៈទ្វេរ(ផ្គួប)ឡើយ។ សម្រាប់ឧបករណ៍ហិរញ្ញវត្ថុបែបនេះ អង្គភាពត្រូវអនុវត្ត កថាខណ្ឌ ៣៩(ក)។

ខ១១ខ កថាខណ្ឌ ៣៩(ខ) តម្រូវឲ្យអង្គភាពលាតត្រដាងការវិភាគបក្កភាពបែបបរិមាណវិស័យ សម្រាប់បំណុលហិរញ្ញវត្ថុនិស្សន្ទ ដែលបង្ហាញបក្កភាពតាមកិច្ចសន្យាដែលនៅសល់ ប្រសិនបើ បក្កភាពតាមកិច្ចសន្យាមានសារៈសំខាន់សម្រាប់ការយល់ដឹងពីពេលវេលានៃលំហូរសាច់ប្រាក់។ ឧទាហរណ៍នេះគឺជាករណីសម្រាប់:

(ក) កិច្ចសន្យាដោះដូរអត្រាការប្រាក់ ដែលមានបក្កភាពនៅសល់ចំនួនប្រាំឆ្នាំនៅក្នុងលំហូរសាច់ការទប់ស្កាត់ហានិភ័យលំហូរប្រាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុឬបំណុលហិរញ្ញវត្ថុដែលមានអត្រាប្រែប្រួល។

(ខ) ការតាំងចិត្តសងប្រាក់កម្ចីទាំងអស់។

ខ១១គ កថាខណ្ឌ ៣៩(ក)និង(ខ)តម្រូវឲ្យអង្គភាពលាតត្រដាងការវិភាគ បក្កភាពសម្រាប់បំណុលហិរញ្ញវត្ថុដែលបង្ហាញពីកាលបក្កភាពតាមកិច្ចសន្យា ដែលនៅសល់ សម្រាប់បំណុលហិរញ្ញវត្ថុមួយចំនួន។ នៅក្នុងការលាតត្រដាងនេះ÷

(ក) នៅពេលដែល ដៃគូរមានជម្រើសអំពីពេលវេលា នៃការបង់សង, បំណុលនឹងត្រូវបែងចែកទៅកាវិយបរិច្ឆេទដំបូងបំផុតដែលអង្គភាព ត្រូវ

បានតម្រូវឲ្យបង់សង។ ឧទាហរណ៍ បំណុលហិរញ្ញវត្ថុ ដែលអង្គភាពអាចត្រូវបានគេតម្រូវឲ្យបង់ សងតាមកាលកំណត់ (ឧ. ប្រាក់បញ្ញើតាមកាលកំណត់) ត្រូវបានដាក់បញ្ចូលទៅក្នុងក្រុមនៃពេលវេលាដំបូងបំផុត។

(ខ)នៅពេលអង្គភាពត្រូវតាំងចិត្តនៅក្នុងការបង់សងជាដំណាក់ៗ ការបង់សងជាដំណាក់និមួយៗ ត្រូវបានបែងចែកទៅ ការិយបរិច្ឆេទដំបូងបំផុតដែលអង្គភាព អាចត្រូវបានតម្រូវឲ្យបង់សង។ ឧទាហរណ៍បរិមាណប្រាក់កម្ចីដែលមិនទាន់ដក នឹងត្រូវបានរាប់បញ្ចូល នៅក្នុងក្រុមនៃពេលវេលាដែលរួមមានកាលបរិច្ឆេទដំបូងបំផុត ដែលអង្គភាពអាចកំណត់បាន។

(គ) សម្រាប់កិច្ចព្រមព្រៀងធានាហិរញ្ញវត្ថុដែលបានចេញផ្សាយបរិមាណអតិបរមានៃការធានាត្រូវបានបែងចែកទៅ កាវិយបរច្ឆេទដំបូងបំផុតដែលកិច្ចព្រមព្រៀងធានាអាចត្រូវបានគេស្នើសុំ។

ខ១១ឃ បរិមាណតាមកិច្ចសន្យាដែលបានបង្ហាញនៅក្នុងការវិភាគបក្កភាពដូចដែលបានតម្រូវដោយកថាខណ្ឌ៣ ៩(ក) និង (ខ) គឺជាលំហូរសាច់ប្រាក់មិនទាន់ធ្វើអប្បហារ, ឧទាហរណ៍ៈ

(ក) កាតព្វកិច្ចភតិសន្យាហិរញ្ញវត្ថុដុល (មុនពេលដកចេញការចំណាយហិរញ្ញវត្ថុ)

(ខ) ថ្លៃដែលបានបញ្ជាក់ នៅក្នុងកិច្ចសន្យាសម្រាប់អនាគត ដើម្បីទិញទ្រព្យសកម្មហិរញ្ញវត្ថុជាសាច់ប្រាក់

(គ) បរិមាណសុទ្ធសម្រាប់កិច្ចព្រមព្រៀងដោះដូរអត្រាការប្រាក់ថេរ /ប្រែប្រួលដែលនៅក្នុងនោះលំហូរសាច់ប្រាក់ត្រូវបានដោះដូរ

(ឃ) បរិមាណតាមកិច្ចសន្យាដែលនឹងត្រូវដោះដូរនៅក្នុងឧបករណ៍ហិរញ្ញ-វត្ថុនិស្សន្ទ (ឧ. កិច្ចព្រមព្រៀងដោះដូររូបិយវត្ថុ) ដែលនៅក្នុងនោះលំហូរ

សាច់ប្រាក់ដុលត្រូវបានគេដោះដូរ និង

(ង)ការតាំងចិត្តសងប្រាក់កម្ចីដុល

លំហូរសាច់ប្រាក់ មិនទានធ្វើអប្បហារខុសគ្នាពីបរិមាណ ដែលត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ពីព្រោះបរិមាណនៅក្នុងរបាយការណ៍នោះត្រូវផ្អែកលើលំហូរសាច់ប្រាក់បានធ្វើអប្បហារួច។ នៅពេលដែលបរិមាណត្រូវបង់មិនថេរ បរិមាណដែលត្រូវលាតត្រដាង ត្រូវតែកំណត់ ដោយសេចក្តីយោងទៅនឹងលក្ខខណ្ឌ ដែលមានស្រាប់ នាចុងការិយបរិច្ឆេទរាយការណ៍។ ឧទាហរណ៍ នៅពេលបរមាណ ត្រូវសងប្រែប្រួល ដោយការផ្លាស់ប្តូរនៅក្នុងសន្ទស្សន៍បរិមាណ ដែលបានលាតត្រដាងអាចត្រូវផ្អែកលើកម្រិតនៃសន្ទស្សន៍នៅចុងការិយបរិច្ឆេទ។

ខ១១ង កថាខណ្ឌ ៣៩(គ) តម្រូវឲ្យអង្គភាពបរិយាយពីរបៀប ដែលអង្គភាពគ្រប់គ្រងហានិភ័យសន្ទនីយភាពដែលមាននៅក្នុងបណ្តាធាតុ ដែលដាក់បង្ហាញនៅក្នុងការការលាតត្រដាងបែបបរោមាណវិស័យ ដែលបានតម្រូវនៅក្នុងកថាខណ្ឌ៣ ៩(ក) និង(ខ)។ អង្គភាពត្រូវលាតត្រដាងការវិភាគបក្កភាពរបស់ទ្រព្យសកម្មហិរញ្ញវត្ថុដែលអង្គភាពរក្សាទុកសម្រាប់គ្រប់គ្រងហានិភ័យសន្ទនីយភាព (ឧ. ឧបករណ៍ហិរញ្ញវត្ថុដែលត្រៀមសម្រាប់លក់ឬដែលត្រូវបានរំពឹងថានឹងបង្កើតសាច់ប្រាក់ចូល ដើម្បីឆ្លើយតបទៅនឹងលំហូរសាច់ប្រាក់ចេញលើបំណុលហិរញ្ញវត្ថុ), ប្រសិនបើព័ត៌មាននោះមានភាពចាំបាច់ដើម្បី ឲ្យអ្នកប្រើរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពវាយតម្លៃពីចរិតលក្ខណៈនិទំហំនៃហានិភ័យសន្ទនីយភាព។

ថ១១ច កត្តាផ្សេងៗទៀតដែលអង្គភាពអាចពិចារណានៅក្នុងការផ្តល់ឲ្យនៅក្នុងការលាតត្រដាងដែលបានតម្រូវនៅក្នុងកថាខណ្ឌ ៣៩(គ) ដែលរួមមាន ប៉ុន្តែមិនកំណត់ត្រឹម ថាតើអង្គភាព:

(ក) ឧបករណ៍សម្រួលប្រាក់កម្ចីដែលត្រូវធ្វើ (ឱ. ឧបករណ៍សម្រួលហិរញ្ញវត្ថុជាបណ្ណ័បំណុលសាជីវកម្ម) ឬកម្រិតឥណទានផ្សេងៗ (ឧបករណ៍សម្រួលហិរញ្ញវត្ថុជាឥណទានសម្រាប់ទ្រទ្រង់) ដែលអង្គភាពអាចឆ្លើយតបបានទៅនឹងសេចក្តីត្រូវការសន្ទនីយភាព,

(ខ) រក្សាទុកប្រាក់បញ្ញើ នៅធនាគារកណ្តាល ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការសន្ទនីយភាព,

(គ) មានប្រភពទិនផ្សេងៗគ្នាច្រើនប្រភេទ

(ឃ) មានបណ្តុំហានិភ័យសន្ទនីយភាពចំបងៗនៅក្នុងទ្រព្យសកម្ម ឬប្រភពទុននានារបស់អង្គភាព

(ង) មានប្រពន្ធ័ នៃការត្រួតពិនិត្យផ្ទៃក្នុង និងមានផែនការ យថាភាពសម្រាប់ការគ្រប់គ្រងហានិភ័យសន្ទីយភាព

(ច) មានឧបករណ៍ហិរញ្ញវត្ថុ ដែលរួមមាននៅលក្ខខណ្ឌនៃការទូទាត់សងរហ័ស (ឱ. ការបន្ថយកម្រិតថ្នាក់នៃចំណាត់ថ្នាក់ឥណទានរបស់អង្គភាព,

(ជ) មានឧបករណ៍ហិរញ្ញវត្ថុ ដែលអាចតម្រូវឲ្យដាក់ ទ្រព្យដាក់បញ្ចាំ (ឱ. សេចក្តីត្រូវការបន្ថែមរបស់និស្សន្ទ)

(ឈ) មានឧបករណ៍ហិរញ្ញវត្ថុដែលអនុញ្ញាតឲ្យអង្គភាពជ្រើសរើស នូវការទូទាត់បំណុលហិរញ្ញវត្ថុដោយបង់សាច់ប្រាក់(ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេង) ឬ ដោយ ការសងជាបណ្ណ័ភាគហ៊ុន, ឬ

(ញ) ឧបករណ៍ហិរញ្ញវត្ថុដែលមានចែងពីកិច្ចព្រមព្រៀងអនុវត្តសិទ្ធិ។

១១២-១១៦ [លុបចោល]

## ហានិភ័យទីផ្សារ-ការវិភាគវេទយិតភាព (កថាខណ្ឌ៤០ និង ៤១)

១១៧ កថាខណ្ឌ៤០(ក)តម្រូវឲ្យធ្វើការវិភាគវេទយិតភាពសម្រាប់ប្រភេទនិមួយៗនៃហានិភ័យទីផ្សារដែលអង្គភាពត្រូវប្រឈម។ យោងតាមកថាខណ្ឌ ខ៣, អង្គភាពសម្រេចពីរបៀបដែលខ្លួនត្រូវប្រមូលផ្តុំពត៌មានដើម្បីបង្ហាញពីទិដ្ឋភាពរួម ដោយមិនរួមបញ្ចូលជាមួយនឹងព័ត៌មាន ដែលមានចរិតលក្ខណៈផ្សេងៗគ្នា ស្តីអំពីការប្រឈមនឹងហានិភ័យ ដែលកើតចេញពីបរិយាកាសសេដ្ឋកិច្ចដែលខុសគ្នាចំបងៗ។ ឧទាហរណ៍:

(ក) អង្គភាពដែលជួញដូរឧបករណ៍ហិរញ្ញវត្ថុអាចលាតត្រដាងព័ត៌មាននេះដាច់ដោយឡែកពីឧបករណ៍ហិរញ្ញវត្ថុដែលរក្សាទុកសម្រាប់ការជួញដូរ និងឧបករណ៍ហិរញ្ញវត្ថុដែលមិនរក្សាទុកសម្រាប់ការជួញដូរ។

(ខ)អង្គភាពមិនត្រូវប្រមូលផ្តុំការប្រឈមនឹងហានិភ័យទីផ្សារដែលកើតចេញពីវិស័យដែលមានអតិផរណាលោតផ្លោះ ជាមួយនឹងការប្រឈមទៅនឹង ហានិភ័យទីផ្សារដូចគ្នា ដែលកើតចេញពីវិស័យ ដែលមានហានិភ័យទាបបំផុត។ ប្រសិនបើអង្គភាពមានការប្រឈម ហានិភ័យទីផ្សារ តែមួយប្រភេទនៅក្នុងបរិយាកាសេដ្ឋកិច្ចតែមួយ, អង្គភាពអង្គភាពមិនត្រូវពង្រាយព័ត៌មាន នោះដែរ។

១១៨ កថាខណ្ឌ ៤០(ក) តម្រូវឲ្យធ្វើការវិភាគវេទយិតភាពដើម្បីបង្ហាញផលប៉ះពាល់លើប្រាក់ចំណេញឬខាតនិងទ្រព្យម្ចាស់នៃការផ្លាស់ប្តូរ ដែលអាចកើតមានដ៏សមសហេតុផល នៅក្នុងអថេរហានិភ័យពាក់ពន្ធ័ (ឧ. អត្រា

ការប្រាក់ទីផ្សារបច្ចុប្បន្ន, អត្រាប្តូរប្រាក់បរទេស (ឬ) ... 

ការប្រាក់ទីផ្សារបច្ចុប្បន្ន, អត្រាប្តូរបិយវត្ថុ, ថ្លៃនៃទ្រព្យម្ចាស់ឬថ្លៃភូមិឌីធី)។ សម្រាប់គោលបំណងនេះ÷

(ក) អង្គភាពមិនត្រូវបានតម្រូវឲ្យកំណត់ចំណេញ ឬខាត នៅក្នុងការិយបរិច្ឆេទ ប្រសិនបើអថេរហានិភ័យពាក់ពន្ធ័មាន លក្ខណៈខុសគ្នា។ ផ្ទុយទៅវិញ អង្គភាពលាតត្រដាងនូវផលប៉ះពាល់លើ ចំណេញ ឬខាត និងលើទ្រព្យម្ចាស់នាចុងការិយបរិច្ឆេទរាយការណ៍ ដោយសន្មត់ថា ការផ្លាស់ប្តូរដែលអាចកើតមានដ៏សមសហេតុផល នៅក្នុងអថេរហានិភ័យពាក់ពន្ធ័បានកើតឡើងនាចុងការិយបរិច្ឆេទរាយការណ៍ និងត្រូវបានអនុវត្ត ចំពោះការប្រឈមហានិភ័យ ដែលកើតឡើងនៅកាលបរិច្ឆេទនោះ។ ឧទាហរណ៍ប្រសិនបើអង្គភាពមានបំណុលដែលមានអត្រាការប្រាក់អណ្តែតនៅចុងឆ្នាំ, អង្គភាពត្រូវ លាតត្រដាងនូវផលប៉ះពាល់លើចំណេញ ឬខាត (នោះគឺជាចំណាយការប្រាក់) សម្រាប់ឆ្នាំបច្ចុប្បន្ន ប្រសិនបើអត្រាការប្រាក់មានការប្រែប្រួលដោយបរិមាណដែលអាចកើតមានដោយសមហេតុផល។

(ខ) អង្គភាពមិនត្រូវបានតម្រូវឲ្យលាតត្រដាងនូវផលប៉ះពាល់លើចំណេញ ឬខាត និងលើទ្រព្យម្ចាស់ សម្រាប់ការផ្លាស់ប្តូរនិមួយៗ ដែលស្ថិតនៅក្នុងលំដាប់នៃការផ្លាស់ប្តូរដែលអាចកើតមានដោយសមហេតុផលនៃអថេរហានិភ័យពាក់ពន្ធ័។ ការលាតត្រដាងអំពីផលប៉ះពាល់នៃការផ្លាស់ប្តូរ តាមកម្រិតនៃលំដាប់ ដែលអាចកើតមានប្រកបដោយហេតុផលសមស្របនឹងមានភាពគ្រប់គ្រាន់។

១១៩ នៅក្នុងការកំណត់អំពីការផ្លាស់ប្តូរដែលអាចកើតមាន ដោយមានហេតុផលសមស្របនៅក្នុងអថេរហានិភ័យពាក់ពន្ធ័, អង្គភាពត្រូវពិចារណាៈ

(ក) បរិយាកាសេដ្ឋកិច្ចដែលអង្គភាពធ្វើអាជីវកម្ម។ ការផ្លាស់ប្តូរ ដែលអាចកើតមាន ដោយមានហេតុផលសមស្របមិនត្រូវដាក់ចូល សេណារីយ៉ូករណីដែល កើតឡើងពីយូរមកហើយឬ "ករណីដែលអាក្រក់បំផុត" ឬ "តេស្តស្ត្រេស"។ ជាងនេះទៀត ប្រសិនបើ អត្រានៃការផ្លាស់ប្តូរនៅក្នុងអថេរហានិភ័យជាមូលដ្ឋានមានស្ថេរភាព, អង្គភាពមិនចាំបាច់ប្តូរការផ្លាស់ប្តូរដែលអាចកើតមានដោយមានហេតុផលសមស្របនៅក្នុងអថេរហានិភ័យឡើយ។ ឧទាហរណ៍, សន្មត់ថាអត្រាការប្រាក់គឺ ៥ភាគរយ ហើយអង្គភាពកំណត់ថាការឡើងចុះនៃអត្រាការប្រាក់មានកម្រិត ±៥០ ចំណុចគោល គឺជាចំនួនដែលអាចកើតឡើងដោយសមហេតុផល។ អង្គភាពនឹងត្រូវលាតត្រដាងនូវផលប៉ះពាល់លើចំណេញ ឬខាត និងលើទ្រព្យម្ចាស់ ប្រសិនបើអត្រាការប្រាក់ត្រូវផ្លាស់ប្តូរពី ៤.៥ភាគរយ ទៅ ៥.៥ភាគរយ។ នៅការិយបរិច្ឆេទបន្ទាប់ អត្រាការប្រាក់ នឹងកើនដល់ ៥.៥ភាគរយ។ អង្គភាពបន្តជឿជាក់ថា អត្រាការប្រាក់អាចឡើងចុះក្នុងកម្រិត ±៥០ចំណុចគោល (មានន័យថា អត្រាប្រែប្រួល នៃអត្រាការប្រាក់មានលំនឹង)។ អង្គភាព នឹងត្រូវលាតត្រដាងផលប៉ះពាល់លើចំណេញ ឬខាត និងលើទ្រព្យម្ចាស់ ប្រសិនបើអត្រាការប្រាក់ត្រូវប្រែប្រួលចាប់ពី ៥ភាគរយ ទៅ ៦ភាគរយ។ អង្គភាពមិនត្រូវបានតម្រូវឱ្យពិនិត្យឡើងវិញនូវការវាយតម្លៃរបស់ខ្លួនដែលអត្រាការប្រាក់អាចឡើងចុះ ដោយសមហេតុផលក្នុងកម្រិត ±៥០ចំណុចគោល, ដរាបណាមានភស្តុតាងមកបញ្ជាក់ថា អត្រាការប្រាក់មានការប្រែប្រួលយ៉ាងខ្លាំង។

(ខ) កាលវេលា ដែលអង្គភាពត្រូវធ្វើការវាយតម្លៃ។ការវិភាគវេតយិតភាពត្រូវបង្ហាញពីផលប៉ះពាល់ នៃការផ្លាស់ប្តូរដែលត្រូវបានពិចារណាថាអាច

កើតឡើង ដោយសមហេតុផលនៅក្នុងអំឡុងការិយបរិច្ឆេទ រហូតដល់អង្គភាព ត្រូវបង្ហាញនៅ ការិយបរិច្ឆេទបន្ទាប់នូវការលាតត្រដាងទាំងនេះដែលជាធម្មតាគឺជាការិយបរិច្ឆេទរាយការណ៍ប្រចាំឆ្នាំខាងមុខបន្ទាប់។

ខ២០ កថាខណ្ឌ ៤១ អនុញ្ញាតឲ្យអង្គភាពប្រើការវិភាគវេទយិតភាព ដែលឆ្លុះបញ្ចាំងអន្តរានិស្សរភាពរវាងថេរហានិភ័យទាំងអស់, ដូចជា វិធីសាស្ត្រការវាយតម្លៃតាមកម្រិតហានិភ័យ, ប្រសិនបើ អង្គភាពប្រើវិធីសាស្ត្រនេះដើម្បីគ្រប់គ្រងការប្រឈមរបស់ខ្លួនទៅនឹងហានិភ័យហិរញ្ញវត្ថុ ។ ប្រការនេះ អនុវត្តន៍បានតែក្នុងករណីដែលវិធីសាស្ត្រនេះវាស់វែងតែពីសក្តានុពលនៃការខាតបង់ និងមិនវាស់វែងពីសក្តានុពលនៃផលចំណេញឡើយ។ អង្គភាព អាចអនុលោមតាមកថាខណ្ឌ ៤១(ក) ដោយការលាតត្រដាងប្រភេទនៃម៉ូឌែលកំណត់តម្លៃតាមកម្រិតហានិភ័យដែលបានប្រើ (ឧ.ថាតើវិធីសាស្ត្រនោះ ពឹងផ្អែកលើវិធីសាស្ត្រម៉ុងតេកាឡូ (Monte Carlo simulations) ឬ យ៉ាងណា), ការពន្យល់អំពីរបៀបដែលម៉ូឌែលត្រូវបានប្រើ និងសម្មិតិកម្ម សំខាន់ៗ (ឧ. រយៈពេលរក្សាទុក និងកម្រិតនៃភាពជឿជាក់) ។ អង្គភាព អាចលាតត្រដាងផងដែររយៈពេលនៃការអង្កេតកន្លងមក និងមធ្យមទំងន់ ដែលបានប្រើចំពោះការអង្កេតនៅក្នុងរយៈពេលនោះ, ការពន្យល់អំពី របៀបដែលជម្រើសត្រូវបានដោះស្រាយនៅក្នុងការគណនានានា, និងភាពឆាប់ប្រែប្រួលនិងសហសម្ពន្ធ័ណាមួយ (ឬ ម៉្យាងវិញទៀត, វិធីសាស្ត្របំណែងចែកប្រូបាប៊ីលីតេតាមម៉ុងតេកាឡូ) ត្រូវបានប្រើ។

ខ២១ អង្គភាពត្រូវផ្តល់នូវការវិភាគវេទយិតភាពសម្រាប់អាជីវកម្មទាំងមូល, ប៉ុន្តែអាចផ្តល់នូវប្រភេទផ្សេងៗគ្នានៃការវិភាគវេទយិតភាពសម្រាប់ថ្នាក់ផ្សេងៗគ្នានៃឧបករណ៍ហិរញ្ញវត្ថុ។

## ហានិភ័យអត្រាការប្រាក់

១២២ ហានិភ័យអត្រាការប្រាក់កើតឡើងនៅលើឧបករណ៍ហិរញ្ញវត្ថុ ដែលជាប់ការប្រាក់ដែលបានទទួលស្គាល់ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ឧ. ឧបករណ៍ហិរញ្ញវត្ថុបំណុល ដែលបានទទួលឬបានបោះផ្សាយ) និងឧបករណ៍ហិរញ្ញវត្ថុមួយចំនួនដែលមិនទទួលស្គាល់ នៅក្នុងរបាយការណ៍ស្ថានភាព ហិរញ្ញវត្ថុ (ឧ. ការតាំងចិត្តសងបំណុលមួយចំនួន)។

## ហានិភ័យរូបិយវត្ថុ

១២៣ ហានិភ័យរូបិយវត្ថុ (ឬ ហានិផ័យអត្រាប្ដូរប្រាក់បរទេស) កើតលើឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានប្រើនូវរូបិយវត្ថុបរទេស មានន័យថា ជារូបិយវត្ថុដែលមិនមែនជារូបិយវត្ថុមុខងារ ដែលឧបករណ៍ហិរញ្ញវត្ថុទាំងនោះត្រូវបានវាស់វែង។ សម្រាប់គោលបំណង នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ ហានិភ័យរូបិយវត្ថុមិនកើតឡើងពីឧបករណ៍ហិរញ្ញវត្ថុដែលជាធាតុមិនមែនរូបិយវត្ថុ ឬពីឧបករណ៍ហិរញ្ញវត្ថុ ដែលមិនប្រើរូបិយវត្ថុមុខងារឡើយ។

១២៤ ការវិភាគវេទយិតភាពត្រូវបានលាតត្រដាងសម្រាប់ប្រភេទរូបិយវត្ថុនិមួយៗ ដែកអង្គភាពមានការប្រឈមនឹងហានិភ័យខ្លាំងក្លា។

## ហានិភ័យថ្លៃផ្សេងៗ

១២៥ ហានិភ័យថ្លៃផ្សេងៗកើតឡើងលើឧបករណ៍ហិរញ្ញវត្ថុដោយសារការផ្លាស់ប្ដូរ ឧទាហរណ៍ ថ្លៃរបស់កុំម៉ូឌីធីឬថ្លៃរបស់ទ្រព្យម្ចាស់។ ដើម្បីអនុលោមតាមកថាខណ្ឌ៤០, អង្គភាពអាចលាតត្រដាងផលប៉ះពាល់នៃការធ្លាក់ចុះ នៅ

ក្នុងសន្ទស្ស ទីផ្សារបណ្ណ៍ភាគហ៊ុនដ៏ជាក់លាក់មួយ, ថ្លៃរបស់កុំម៉ូឌីធី ឬអថេរហានិភ័យផ្សេងៗទៀត។ឧទាហរណ៍ ប្រសិនបើ អង្គភាពផ្តល់ការធានាលើតម្លៃសំណល់ដែលជាឧបករណ៍ហិរញ្ញវត្ថុ, អង្គភាពត្រូវលាតត្រដាងនូវការកើនឡើងឬការថយចុះនៃតម្លៃទ្រព្យសកម្មដែលការធានានោះអនុវត្តលើ។

១២៦ ឧទាហរណ៍ពីរ នៃឧបករណ៍ហិរញ្ញវត្ថុ ដែលធ្វើឲ្យកើនហានិភ័យថ្លៃរបស់ទ្រព្យម្ចាស់គឺ (ក) កាន់កាប់បណ្ណ៍ភាគហ៊ុននៅក្នុង ក្រុមហ៊ុនដ៏ទៃ និង (ខ) ការវិនិយោគនៅក្នុងបរធនបាល (ត្រាស់) ដែលទទួលបានមកវិញជាការវិនិយោគនៅក្នុងឧបករណ៍ហិរញ្ញវត្ថុទ្រព្យម្ចាស់។ ឧទាហរណ៍ផ្សេងទៀត គឺកិច្ចសន្យា សម្រាប់ការអនុវត្តពេលអនាគត (forward contract) និងជម្រើសពិសេសសម្រាប់ទិញឬលក់បរិមាណជាក់លាក់មួយនៃឧបករណ៍-ហិរញ្ញវបត្ថុទ្រព្យម្ចាស់ និងកិច្ចព្រមព្រៀងដោះដូរឧបករណ៍ហិរញ្ញវត្ថុដែលធ្វើ ជាសន្ទស្សថ្លៃរបស់ទ្រព្យម្ចាស់។តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុ ត្រូវបានទទួលរងផលប៉ះពាល់ដោយការផ្លាស់ប្តូរនៅក្នុងថ្លៃទីផ្សារនៃឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន។

១២៧ ដោយយោងតាមកថាខណ្ឌ ៤០(ក), វេទយិតភាពនៃចំណេញ ឬខាត (ដែលកើតពី ឧទាហរណ៍ ឧបករណ៍ហិរញ្ញវត្ថុដែល បានវាស់វែងតាមតម្លៃសមស្របនៅក្នុងផ្នែករបាយការណ៍ចំណេញ ឬខាត) ត្រូវបានលាតត្រដាងដាច់ដោយឡែកពីគ្នាពី វេទយិតភាពនៃចណ្ណូលបន្ទាប់បន្សំផ្សេងៗ (ដែលកើតពីឧទាហរណ៍ ការវិនិយោគនៅក្នុងឧបករណ៍ហិរញ្ញវត្ថុដែលការផ្លាស់ប្តូរតម្លៃសមស្របត្រូវបានបង្ហាញនៅក្នុងផ្នែកចំណូលបន្ទាប់បន្សំផ្សេងៗ)។

១២៨ ឧបករណ៍ហិរញ្ញវត្ថុ ដែលអង្គភាពចាត់ថ្នាក់ថាជាឧបករណ៍ហិរញ្ញវត្ថុ ទ្រព្យម្ចាស់ មិនត្រូវបានវាស់វែងឡើងវិញទេ។ ទាំងចំផ្នែកចំណេញ ឬខាត ឬទ្រព្យម្ចាស់មិនទទួលរង ដោយហានិភ័យថ្លៃរបស់ទ្រព្យម្ចាស់នៃឧបករណ៍ហិរញ្ញវត្ថុទាំងនោះឡើយ។ ទន្ទឹងនឹងនេះ វាមិនតម្រូវឲ្យមានការវិភាគវេទយិតភាពឡើយ។

## ការមិនទទួលស្គាល់ (កថាខណ្ឌ ៤២គ-៤២ថ)

### ការពាក់ព័ន្ធបន្ត(កថាខណ្ឌ ៤២ឥ)

១២៩ ការវាយតម្លៃនូវភាពពាក់ព័ន្ធបន្ត នៅក្នុងទ្រព្យសកម្មហិរញ្ញវត្ថុ បានផ្ទេរសម្រាប់គោលបំណង នៃតម្រូវការសម្រាប់ការលាតព័ត៌មាន នៅក្នុងកថាខណ្ឌ ៤២ង-៤២ថ ត្រូវបានធ្វើនៅកម្រិត នៃអង្គភាពរាយការណ៍។ ឧទាហរណ៍ ប្រសិនបើក្រុមហ៊ុនបុត្រសម្ព័ន្ធផ្ទេរទ្រព្យសកម្មហិរញ្ញវត្ថុ ទៅភាគីទីបីដែលមិនពាក់ព័ន្ធ ដែលនៅក្នុងនោះក្រុមហ៊ុនមេ នៃក្រុមហ៊ុនបុត្រសម្ព័ន្ធ មានភាពពាក់ព័ន្ធបន្ត, ក្រុមហ៊ុនបុត្រសម្ព័ន្ធមិនរាប់បញ្ចូលការពាក់ព័ន្ធរបស់ក្រុមហ៊ុនមេនៅក្នុងការវាយតម្លៃ ថាតើខ្លួនមានការពាក់ព័ន្ធបន្តនៅក្នុងទ្រព្យសកម្មដែលបានផ្ទេរនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់តែឯង (មានន័យថា នៅពេលដែលក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺជាអង្គភាពរាយការណ៍)។ ទោះជាយ៉ាងណា ក្រុមហ៊ុនមេនឹងដាក់បញ្ចូលភាពជាប់ពាក់ព័ន្ធបន្តរបស់ខ្លួន (ឬ ភាពជាប់បាក់ព័ន្ធបន្តរបស់សមាជិកផ្សេងទៀតនៅក្នុងគ្រុប) ជានឹងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានផ្ទេរ ដោយក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួននៅក្នុងការកំណត់ថាតើ ខ្លួនមានការពាក់ព័ន្ធបន្តជាមួយនឹងទ្រព្យសកម្មបានផ្ទេរនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម (មានន័យថា នៅពេលដែលអង្គភាពរាយការណ៍គឺជាគ្រុប)។

១៣០ អង្គភាព មិនមានភាពជាប់ពាក់ព័ន្ធបន្ត ជាមួយនឹងទ្រព្យសកម្មបានផ្ទេរ ប្រសិនបើ ដែលជាផ្នែកមួយនៃការផ្ទេរ អង្គភាពមិនរក្សាទុកសិទ្ធិណាមួយនៅក្នុងកិច្ចសន្យា ឬកាតព្វកិច្ចដែលមាននៅក្នុងទ្រព្យសកម្មហិរញ្ញវត្ថុដែលបានផ្ទេរ ឬមិនទទួល បាននូវសិទ្ធិតាមកិច្ចសន្យា ឬកាតព្វកិច្ចទាក់ទងនឹងទ្រព្យសកម្មហិរញ្ញវត្ថុបានផ្ទេរ។ អង្គភាពមួយមិនមានការពាក់ព័ន្ធបន្ត ជាមួយនឹងទ្រព្យសកម្មហិរញ្ញវត្ថុបានផ្ទេរ ប្រសិនបើ អង្គភាពនោះមិនមានភាគកម្មណាមួយនៅក្នុងលទ្ធផល នាពេលអនាគតរបស់ទ្រព្យសកម្មហិរញ្ញវត្ថុបានផ្ទេរ ឬមិនមានការទទួលខុសត្រូវក្រោមកាលៈទេសៈណាមួយ ដើម្បីធ្វើការបង់សងពាក់ព័ន្ធនឹងទ្រព្យសកម្មហិរញ្ញវត្ថុនាពេលអនាគត។

១៣១ ការពាក់ព័ន្ធបន្តជាមួយនឹងទ្រព្យសកម្មហិរញ្ញវត្ថុបានផ្ទេរមួយ អាចបណ្តាលមកពីសេចក្តីថែងក្នុងកិច្ចសន្យានីក្នុងកិច្ចព្រមព្រៀងនៃការផ្ទេរ ឬនៅក្នុងកិច្ចព្រមព្រៀងដាច់ដោយឡែកជាមួយអ្នកទទួលការផ្ទេរ ឬភាគីទីបី ដែលមានការពាក់ព័ន្ធនឹងការផ្ទេរ។

## ទ្រព្យសកម្មបានផ្ទេរដែលមិនត្រូវបានមិនទទួលស្គាល់ទាំងស្រុង

១៣២ កថាខណ្ឌ ៤០យ តម្រូវឱ្យធ្វើការលាតត្រដាង នៅពេលដែលមួយផ្នែក ឬផ្នែកទាំងមូលនៃទ្រព្យសកម្មហិរញ្ញវត្ថុបានផ្ទេរ មិនមានគុណវុឌ្ឍ សម្រាប់ការមិនទទួលស្គាល់។ ការលាតត្រដាងទាំងនោះត្រូវបានតម្រូវឱ្យធ្វើ នាកាលបរិច្ឆេទរាយការណ៍និមួយៗ ដែលជាពេល ដែលអង្គភាពបន្តទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុបានផ្ទេរ បើទោះបីការផ្ទេរបានកើត ឡើងពេលណាក៏ដោយ។

## ប្រភេទនៃការពាក់ពន្ធ័បន្ត (កថាខណ្ឌ ៤២ង-៤២ច)

ខ៣៣ កថាខណ្ឌ ៤២ង-៤២ច តម្រូវឱ្យមានការលាតត្រដាងបែបបរិមាណវិស័យ និងបែបគុណវិស័យសម្រាប់ប្រភេទនិមួយៗ នៃការពាក់ពន្ធ័បន្តជាមួយនឹងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនទទួលស្គាល់។ អង្គភាពត្រូវប្រមូលផ្តុំនូវការពាក់ពន្ធ័បន្តរបស់ខ្លួនតាមប្រភេទ នៃឧបករណ៍ហិរញ្ញវត្ថុ (ឧ. ការធានា ឬជម្រើសពិសេសនៃការទិញមកវិញ) ឬតាមប្រភេទនៃការផ្ទេរ (ឧ. ការដាក់បញ្ចាំគណនីត្រូវទទួល, មូលបត្រនីយកម្ម និងកម្ចីធានា)។

## ការវិភាគបក្ខភាពសម្រាប់លំហូរសាច់ប្រាក់ចេញដែលមិនទាន់ធ្វើអប្បហារដើម្បីទិញមកវិញនូវទ្រព្យសកម្មបានផ្ទេរ (កថាខណ្ឌ៤២ង(ង))

ខ៣៤ កថាខណ្ឌ ៤២ង(ង) តម្រូវឱ្យអង្គភាពលាតត្រដាងការវិភាគបក្ខភាព នៃលំហូរសាច់ប្រាក់ចេញ ដែលមិនទាន់ធ្វើអប្បហារ ដើម្បីទិញមកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនទទួលស្គាល់ ឬបរមានទឹកប្រាក់ត្រូវបង់ផ្សេងទៀតទៅអ្នកទទួលការ
ផ្ទេរពាក់ពន្ធ័នឹងទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនទទួលស្គាល់, ដោយបង្ហាញនូវបក្ខភាពដែលនៅសល់តាមកិច្ចសន្យានៃការពាក់ពន្ធ័បន្តរបស់អង្គភាព។ ការវិភាគនេះញែកចេញពីគ្នានូវលំហូរសាច់ប្រាក់ដែលត្រូវបានតម្រូវឱ្យបង់សង (ឧ. កិច្ចសន្យាសម្រាប់ការអនុវត្តនាពេលអនាគត), លំហូរសាច់ប្រាក់ដែលអង្គភាពអាចត្រូវបង់ឱ្យគេ (ឧ. ជម្រើសពិសេស នៃការទិញមកវិញជាលាយលក្សអក្សរ) និងលំហូរសាច់ប្រាក់ ដែលអង្គភាពអាចជ្រើសរើសបង់សង (ឧ. ជម្រើសពិសេស នៃការទិញមកវិញ ដែលបានទិញ)។

១៣៥ អង្គភាពត្រូវប្រើការវិនិច្ឆ័យរបស់ខ្លួន ដើម្បីកំណត់ចំនួនសមស្រប នៃក្រុមពេលវេលានៅក្នុងការរៀបចំការវិភាគបក្ខភាព ដែលបានតម្រូវដោយកថាខណ្ឌ ៤២ង(ង)។ ឧទាហរណ៍ អង្គភាពអាចកំណត់ថា ក្រុមពេលវេលាបក្ខភាពខាងក្រោម មានភាពសមរម្យៈ

(ក) មិនយឺតជាងមួយខែ

(ខ) មិនយឺតជាងមួយខែ និង មិនយឺតជាងបីខែ

(គ) មិនយឺតជាងបីខែ និង មិនយឺតជាងប្រាំមួយខែ

(ឃ) មិនយឺតជាងប្រាំមួយខែ និង មិនយឺតជាងមួយឆ្នាំ

(ង) មិនយឺតជាងមួយឆ្នាំ និង មិនយឺតជាងបីឆ្នាំ

(ច) មិនយឺតជាងបីឆ្នាំ និង មិនយឺតជាងប្រាំឆ្នាំ និង

(ឆ) ច្រើនជាងប្រាំឆ្នាំ ។

១៣៦ ប្រសិនបើ មានលំដាប់នៃបក្ខភាពដែលអាចមាន, លំហូរសាច់ប្រាក់ត្រូវបានដាក់បញ្ចូលដោយផ្អែកលើកាលបរិច្ឆេទដំបូងបំផុតដែលអង្គភាព អាចត្រូវបានតម្រូវសង ឬត្រូវបានអនុញ្ញាតឱ្យសង។

### ព័ត៌មានបែបគុណវិស័យ (កថាខណ្ឌ៤២ង(ច))

១៣៧ ព័ត៌មានបែបគុណវិស័យ ដែលបានតម្រូវដោយកថាខណ្ឌ ៤២ង(ច) រួមមានការបរិយាយអំពីទ្រព្យសកម្មហិរញ្ញវត្ថុដែល មិនទទួលស្គាល់ និងចរិតលក្ខណៈនិងគោលបំណងនៃការពាក់ពន្ធ័បន្តដែលរក្សាទុកបន្ទាប់ពីការផ្ទេរទ្រព្យសកម្មទាំងនោះ។ វាក៏រួមមាននូវការបរិយាយអំពីហានិភ័យ ដែលអង្គភាពត្រូវប្រឈមផងដែរ ដែលរួមមានៈ

(ក) ការបរិយាយអំពីរបៀបដែលអង្គភាពគ្រប់គ្រងហានិភ័យដែលមាននៅក្នុងការពាក់ពន្ធ័បន្តរបស់ខ្លួន ជាមួយនឹងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនទទួលស្គាល់។

(ខ) ថាតើអង្គភាពត្រូវបានតម្រូវឲ្យទទួលខុសត្រូវលើការខាតបង់មុនភាគីផ្សេងទៀតឬយ៉ាងណា, និងចំណាត់ថ្នាក់និង បរិមាណនៃការខាតបង់ដែលបង្ករឡើងដោយភាគីនានាដែលមានភាគកម្មមានចំណាត់ថ្នាក់ទាបជាងភាគកម្មរបស់អង្គភាពនៅក្នុងទ្រព្យសកម្មនោះ (មានន័យថា ការពាក់ពន្ធ័បន្តរបស់អង្គភាពជាមួយនឹងទ្រព្យសកម្ម)។

(គ) ការបរិយាយអំពីគន្លឹះនានាដែលទាក់ទងជាមួយកាតព្វកិច្ចដើម្បីផ្តល់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុ ឬដើម្បីទិញមកវិញទ្រព្យសកម្មហិរញ្ញវត្ថុបានផ្ទេរ។

## ចំណេញឬខាតលើការមិនទទួលស្គាល់ (កថាខណ្ឌ ៤២ឲ(ក)

ខ៣៨ កថាខណ្ឌ ២(ឆ) តម្រូវឲ្យអង្គភាពលាតត្រដាងនូវចំណេញ ឬខាត លើការមិនទទួលស្គាល់ទាក់ទងទៅនឹងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលអង្គភាពមានការពាក់ពន្ធ័បន្ត។អង្គភាពត្រូវលាតត្រដាង ប្រសិនបើចំណេញ ឬខាតលើការមិនទទួលស្គាល់ ដែលបានកើតឡើង ដោយដោយសារតែតម្លៃសមស្រប នៃសមាសធាតុរបស់ទ្រព្យសកម្ម ដែលបានទទួលស្គាល់ពីមុន (មានន័យថា ភាគកម្មនៅក្នុងទ្រព្យសកម្ម ដែលមិនទទួលស្គាល់ និងភាគកម្មដែលបានរក្សាទុកដោយអង្គភាព) ខុសគ្នាពី តម្លៃសមស្រសបរបស់ទ្រព្យសកម្មដែលបានទទួលស្គាល់ពីមុនទាំងមូល។ នៅក្នុងស្ថានភាពនោះ, អង្គភាពត្រូវលាតត្រដាងថា តើការវាស់វែងតម្លៃសមស្របបានរាប់បញ្ចូល

នូវធាតុដ៏សំខាន់ដែលមិនពឹងផ្អែកលើទិន្នន័យទីផ្សារដែលអាចអង្កេតបាន, ដូចបានបរិយាយនៅក្នុងកថាខណ្ឌ ២៧ក។

**ព័ត៌មានបំពេញបន្ថែម (កថាខណ្ឌ៤២ជ)**

១៣៩ ការលាតត្រដាងដែលបានតម្រូវនៅក្នុងកថាខណ្ឌ ៤២ឃ-៤២ង អាចមិនគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងកម្មវត្ថុនៃការលាតត្រដាងនៅក្នុងកថាខណ្ឌ ៤២ខ។ ប្រសិនបើនេះគឺជាករណី, អង្គភាពត្រូវលាតត្រដាងព័ត៌មានបន្ថែមនានាដែលចាំបាច់ដើម្បីឆ្លើយតប ទៅនឹងកម្មវត្ថុ នៃការលាតត្រដាង។ អង្គភាពត្រូវសម្រេច, តាមកាលៈទេសៈរបស់ខ្លួន, បរិមាណនៃព័ត៌មានបន្ថែមដែលអង្គភាពចាំបាច់ត្រូវផ្តល់ឲ្យដើម្បីបំពេញសេចក្តីត្រូវការព័ត៌មានរបស់អ្នកប្រើ និងកម្រិតនៃការផ្តោតរបស់ព័ត៌មាន ដែលអង្គភាពត្រូវដាក់បង្ហាញដោយផ្អែកលើទិដ្ឋភាពផ្សេងៗនៃព័ត៌មានបន្ថែម។ វាជាការចាំបាច់ដែលត្រូវ ធ្វើឲ្យមានតុល្យភាពរវាងបន្ទុកនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលមានសេចក្តីលំអិតខ្លាំងពេក ដែលមិនអាចជួយដល់អ្នកប្រើរបាយការណ៍ហិរញ្ញវត្ថុ និងភាពមិនច្បាស់លាស់នៃព័ត៌មានដែលជាលទ្ធផល នៃការប្រមូលផ្តុំព័ត៌មានច្រើនហួសហេតុពេក។

ក្រុមប្រឹក្សាជាតិគណនេយ្យ
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាសយដ្ឋាន៖ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែល៖ info@naccambodia.gov.kh | គេហទំព័រ៖ www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ